# អង្គការសហប្រជាជាតិ
# សេចក្តីពន្យល់ទូទៅលេខ២ ស្តីពី
# ការបង្កលក្ខណៈងាយស្រួល

## អនុម័តដោយគណៈកម្មាធិការសិទ្ធិជនពិការ ក្នុងសម័យប្រជុំលើកទី១១
## ថ្ងៃទី៣១ មីនា-១១ មេសា ឆ្នាំ២០១៤



អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
កម្ពុជា

ចែកជូនដោយឥតគិតថ្លៃ

# អង្គការសហប្រជាជាតិ

# អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ

## សេចក្តីពន្យល់ទូទៅលេខ២ (២០១៤)

## មាត្រា៩៖ ការបង្កលក្ខណៈងាយស្រួល

*អនុម័តដោយគណៈកម្មាធិការសិទ្ធិជនពិការ*

*ក្នុងសម័យប្រជុំលើកទី១១*

*ថ្ងៃទី៣១ មីនា-១១ មេសា ឆ្នាំ២០១៤*

អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យឧត្តមស្នងការ
*កម្ពុជា*

**ខែមករា ឆ្នាំ២០១៥**

-

# មាតិការឿង

កថាមុខ ..................................................................................................១

ខ្លឹមសារនៃមាត្រា៩ ...........................................................................................៨

I. - សេចក្តីផ្តើមនៃសេចក្តីពន្យល់ទូទៅ..................................១១

II. -ខ្លឹមសារគតិយុត្តិ ......................................................................២៣

III. -កាតព្វកិច្ចរបស់រដ្ឋភាគី ....................................................៤១

IV. - អន្តរទំនាក់ទំនងជាមួយមាត្រាផ្សេងទៀត ......................៤៩

ଔଔଔ✶ ജജജ

# អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ សេចក្តីពន្យល់ទូទៅលេខ២ អំពី មាត្រា៩៖ ការបង្កលក្ខណៈងាយស្រួល

## កថាមុខ

រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២។ អនុសញ្ញាស្តីពីសិទ្ធិជនពិការ ចែងពីសិទ្ធិរបស់ជនពិការក្នុងការរស់នៅដោយឯករាជ្យ ទទួលបានសិទ្ធិមនុស្សរបស់ពួកគេ និងចូលរួមពេញលេញក្នុងជីវភាពសង្គម នយោបាយ និងវប្បធម៌។

ដំណោះស្រាយបញ្ហានៃការបង្កលក្ខណៈងាយស្រួល បង្ហាញពីការផ្លាស់ប្តូរថ្មីដ៏ចំបងមួយនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ គឺជាមូលហេតុគ្រឹះមួយដែលធ្វើឲ្យអនុសញ្ញានេះ ត្រូវបានចាត់ទុកជាអនុសញ្ញាប្រវត្តិសាស្ត្រដែលបង្ហាញឡើងវិញនូវផ្លូវរបស់សង្គម ទាក់ទងនឹងជនពិការ។ ដំណោះស្រាយបញ្ហានៃការបង្កលក្ខណៈងាយស្រួលនៃបរិស្ថានរូបវន្ត មធ្យោបាយធ្វើដំណើរ ពត៌មាននិងទំនាក់ទំនង និងសម្ភារៈបរិក្ខារ និងសេវាកម្មសាធារណៈ មាត្រា៩ នៃអនុសញ្ញាស្តីពីជនពិការ ចែងនៅក្នុងច្បាប់ជាធរមាននូវវិធានការជាក់ស្តែងថា រដ្ឋត្រូវតែមានកាតព្វកិច្ចរ៉ាប់រងដើម្បីធានាឲ្យមានការបង្កលក្ខណៈងាយស្រួលសម្រាប់ជនពិការ។ ឬក្នុងន័យផ្សេងទៀត កង្វះការបង្កលក្ខណៈងាយស្រួល រួមទាំងគ្មានលទ្ធភាពចូលរួមពេញលេញក្នុងសង្គម លែងជាឧបសគ្គតទៅទៀតសម្រាប់ជនពិការក្នុង

ការពុះពារជំនះហើយ ក៏ប៉ុន្តែវាជាការទទួលខុសត្រូវរបស់រដ្ឋក្នុងការកាត់បន្ថយ ប្រសិនជាមិនអាចលុបបំបាត់បានទាំងស្រុង។ ការបង្កលក្ខណៈងាយស្រួល គឺជាគោលការណ៍ទូទៅមួយដែលបានកំនត់នៅក្នុងមាត្រា៣នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ ហើយប្រាប់ពីការបកស្រាយសិទ្ធិទាំងអស់ដែលត្រូវបានការពារនៅក្នុងអនុសញ្ញានេះ។ ការខាកខានមិនបានធានាឱ្យមានការបង្កលក្ខណៈងាយស្រួល លែងគ្រាន់តែជាការអាម៉ាស់ដើម្បីត្អូញត្អែរទៀតហើយ ប៉ុន្តែគឺជាការរំលោភលើគោលការណ៍សិទ្ធិមនុស្សស្នូលនៃសមភាព និងការមិនរើសអើង។

ការយល់ដឹងថ្មីនៃកាតព្វកិច្ចរបស់រដ្ឋ អំពីបញ្ហានៃការបង្កលក្ខណៈងាយស្រួល ត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ដោយគណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធជនពិការ (គណៈកម្មាធិការ) នៅក្នុងសម័យប្រជុំលើកទី១១របស់ខ្លួន កាលពីខែមេសា ឆ្នាំ២០១៤ គណៈកម្មាធិការបានអនុម័តសេចក្តីពន្យល់ទូទៅមួយដើម្បីបញ្ជាក់ពីវិសាលភាព និងអត្ថន័យនៃមាត្រា៩។ គណៈកម្មាធិការដែលមានសមាជិកចំនួន១៨រូប សុទ្ធជាអ្នកជំនាញឯករាជ្យ ដែលត្រូវបានបោះឆ្នោតជ្រើសរើសដោយរដ្ឋភាគីនៃអនុសញ្ញា។ គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងក្រោមមាត្រា៣៤នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ សម្រាប់តាមដានការអនុវត្តអនុសញ្ញានេះរបស់រដ្ឋភាគីទាំងអស់។ គណៈកម្មាធិការពិនិត្យរបាយការណ៍ដែលរដ្ឋភាគីត្រូវដាក់ជូនគណៈកម្មាធិការយ៉ាងទៀងទាត់។ គណៈកម្មាធិការអនុម័តសេចក្តីសង្កេតសន្និដ្ឋានសំរាប់រដ្ឋភាគីនីមួយៗ ដែលក្នុងនោះ ក៏មានបញ្ចូលអនុសាសន៍ពីការកែលម្អដែលត្រូវអនុវត្តស្របតាមអនុសញ្ញា។

សំរាប់ការកែលម្អនេះឲ្យចេញជារូបរាងឡើង រដ្ឋភាគីត្រូវយល់ដោយសមហេតុផលពីប្រភេទ និងទំហំនៃកាតព្វកិច្ចរបស់ខ្លួន ក្រោមអនុសញ្ញានេះ។ ការបរិយាយពីសេចក្តីពន្យល់ទូទៅនេះ គឺជាវិធីមួយដែលគណៈកម្មាធិការផ្តល់ជំនួយសំដៅដល់គោលបំណងនេះ។ តាមរយៈសេចក្តីពន្យល់ទូទៅលើមាត្រានីមួយៗនៃអនុសញ្ញានេះ គណៈកម្មាធិការពន្យល់យ៉ាងលម្អិតពីវិធានការជាក់លាក់ ដោយបានរំពឹងថា រដ្ឋភាគីនឹងបំពេញកាតព្វកិច្ចរបស់ខ្លួនក្រោមមាត្រានេះ។ សេចក្តីពន្យល់ទូទៅនានា ពឹងផ្អែកទាំងស្រុងលើបទពិសោធន៍របស់គណៈកម្មាធិការ ក្នុងការពិនិត្យមើលពីស្ថានភាពនៃការអនុវត្តន៍សន្ធិសញ្ញា នៅក្នុងបណ្តាប្រទេសនានានៅលើពិភពលោកក៏ដូចជាអំពីការអនុវត្តល្អៗជាអន្តរជាតិ។ ការស្វែងរកព័ត៌មានយ៉ាងសកម្មពីអ្នកពាក់ព័ន្ធទាំងអស់ ក្នុងដំណើរការនៃការចងក្រងសេចក្តីពន្យល់ទូទៅ គណៈកម្មាធិការបានទទួលផលច្រើនពីទស្សនវិស័យ និងបទពិសោធន៍ពីរដ្ឋនានា ពីអ្នកជំនាញសិទ្ធិពិការភាព មកពីបណ្ឌិតសភា និងកន្លែងផ្សេងៗទៀត ព្រមទាំងពីអង្គការជនពិការទៀតផង។

យោងតាមសេចក្តីពន្យល់ទូទៅលេខ២ អំពីមាត្រា៩ រដ្ឋភាគីមានកាតព្វកិច្ចកំណត់អត្តសញ្ញាណ រួចហើយលុបបំបាត់ចោលឧបសគ្គទាំងឡាយដែលទាក់ទងនឹងការបង្កលក្ខណៈងាយស្រួល ធ្វើដូច្នេះ ជនពិការអាចទទួលបានពេញលេញ នូវលំហជារូបវន្តទាំងអស់ មធ្យោបាយធ្វើដំណើរ ទំនិញ ផលិតផល ព័ត៌មាន និងសេវាកម្មដែលមានសំរាប់សាធារណៈជនទូទៅ។ ស្តង់ដានៃការបង្កលក្ខណៈងាយស្រួលនេះ អនុវត្តទាំងសម្ភារៈបរិក្ខារផ្តល់ដោយគ្រឹះស្ថានសាធារណៈ និងគ្រឹះស្ថានឯកជន ទាំងនៅទីក្រុង និងនៅជនបទ។ ការខកខានមិនបានធានាឲ្យមានការបង្កលក្ខណៈងាយស្រួលនេះ បង្កើតជាអំពើនៃការរើសអើងមួយ។

រដ្ឋភាគីនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ ត្រូវអនុម័ត ប្រកាសឲ្យប្រើ និងតាមដានឃ្លាំមើលស្តង់ដាជាតិ នៃការបង្កលក្ខណៈងាយស្រួលនេះ។ កិច្ចការនេះត្រូវធ្វើ តាមរយៈការបង្កើតក្របខ័ណ្ឌច្បាប់មួយដែលសមរម្យ ដែលត្រូវបានតាក់តែងឡើង ដោយមានកិច្ចពិគ្រោះយោបល់យ៉ាងជិតស្និត ជាមួយនឹងជនពិការ និងដៃគូពាក់ព័ន្ធដទៃទៀត។ រដ្ឋភាគីនានាអាចពិគ្រោះយោបល់ជាមួយនឹងរដ្ឋភាគីដទៃទៀត ព្រមទាំងអង្គការអន្តរជាតិនានា។ ក្របខ័ណ្ឌនេះត្រូវយកមកពិចារណាផងដែរនូវប្រភេទផ្សេងៗនៃពិការភាព និងត្រូវដោះស្រាយដល់ជនពិការទាំងពីរភេទ និងគ្រប់អាយុទាំងអស់។

កថាខណ្ឌទី១ នៃមាត្រា៩ ដាក់កាតព្វកិច្ចលើរដ្ឋភាគីឲ្យកំណត់អត្តសញ្ញាណ រួចហើយលុបបំបាត់ចោលឧបសគ្គទាំងឡាយដែលទាក់ទងនឹងការបង្កលក្ខណៈងាយស្រួល។ ការបង្កលក្ខណៈងាយស្រួលមានន័យថា បុគ្គលម្នាក់ៗចង់ផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត ឬនៅក្នុងកន្លែងនោះបានដោយសេរី ដោយគ្មានឧបសគ្គរូបវន្តឬព័ត៌មាន។ កិច្ចការនេះអាចសម្រេចបាន ដោយអនុវត្តតាមគោលការណ៍នៃ "ការរចនាប្លង់សកល" ដល់អាគារ យានជំនិះ ព្រមទាំងព័ត៌មាន និងបច្ចេកវិទ្យាទំនាក់ទំនង ដែលជាគំនិត គឺចាប់ពីដំណាក់កាលដំបូងនៃការធ្វើផែនការ និងការសាងសង់។ លក្ខណៈនៃការរចនា នឹងត្រូវបំពេញបន្ថែមដោយការប្រើប្រាស់ជំនួយបច្ចេកទេសនៅពេលណាចាំបាច់។

ទាក់ទងនឹងរចនាសម្ព័ន្ធដែលមានស្រាប់ ទោះបីជាគោលការណ៍ដូចគ្នានេះត្រូវយកមកអនុវត្ត ការអនុវត្តអាចនឹងធ្វើបាន តាមរយៈការកែសម្រួលបន្តិចម្តងៗ ស្របតាមយុត្តិសាស្ត្រដែលបានគ្រងទុក ធ្វើការត្រឡប់ក្រោយ ដើម្បីដករបាំងចេញសម្រួលដល់ការបង្កលក្ខណៈងាយស្រួល។ រដ្ឋភាគីត្រូវរៀបចំអន្តរាគមន៍ដល់ការកសាងសមត្ថភាព សម្រាប់អាជ្ញាធរមូលដ្ឋាន និងស្ថាប័នឃ្លាំមើល អំពីការអនុវត្តច្បាប់ការបង្កលក្ខណៈងាយស្រួល និងការអនុវត្តយុទ្ធសាស្ត្រ។

រដ្ឋភាគីនីមួយៗ មានកាតព្វកិច្ចលើកកម្ពស់ការយល់ដឹងដល់ដៃគូពាក់ព័ន្ធនានាអំពីការបង្កលក្ខណៈងាយស្រួលនេះ រួមទាំងការលើកស្ទួយដល់ការរចនាប្លង់សកល និងស្តង់ដាពាក់ព័ន្ធនានា ព្រមទាំងការទទួលខុសត្រូវ ដែលត្រូវយកមកអនុវត្តស្មើភាពគ្នាចំពោះវិស័យសាធារណៈ និងវិស័យឯកជន។

ការអនុវត្តមាត្រា៩មានសារៈសំខាន់ណាស់ក្នុងការសម្រេចបាននូវគោលបំណងរួមនៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ ដែលត្រូវលើកស្ទួយសមភាព និងសេចក្តីថ្លៃថ្នូររបស់ជនពិការ ដោយបង្កលទ្ធភាពឲ្យជនពិការធ្វើអ្វីដោយឯករាជ្យ និងឱកាសដើម្បីអនុវត្តបានពេញលេញនូវសិទ្ធិមនុស្ស និងសេរីភាព។ ការបង្កលក្ខណៈងាយស្រួលនៃលំហរូបវន្ត ការដឹកជញ្ជូន ព័ត៌មាន ទំនាក់ទំនងនិងសេវាកម្ម គឺជាបុរេលក្ខខណ្ឌចាំបាច់មួយឲ្យជនពិការទទួលបានសិទ្ធិជាច្រើនដែលបានទទួលស្គាល់នៅក្នុងអនុសញ្ញានេះ រួម

ទាំងសិទ្ធិទទួលបានការការពារ និងសិទ្ធិឧបាស្រ័យក្នុងស្ថានភាពអាសន្ន សិទ្ធិទទួលបានសេវាយុត្តិធម៌ ការការពារពីអំពើហិង្សា និងការបំពាន និងសិទ្ធិចូលរួមនយោបាយ។ សិទ្ធិទទួលបានព័ត៌មាន និងទំនាក់ទំនង មានសារៈសំខាន់ដល់ការប្រើប្រាស់សិទ្ធិបញ្ចេញមតិ និងគំនិតដោយសេរី។ សិទ្ធិរបស់មនុស្សម្នាក់ ទទួលបានការអប់រំ ការថែទាំសុខភាព និងទទួលបានការងារដែលមានចំណូល អាចអនុវត្តទៅបានតែក្នុងករណីដែលសាលា មណ្ឌលសុខភាព និងកន្លែងធ្វើការ អាចចេញចូលបានជារូបវន្ត និងជំរុញបរិយាកាសនៃការដាក់បញ្ចូល និងសមភាព។ សិទ្ធិវប្បធម៌ រួមទាំងសិល្បៈ កីឡា និងការកំសាន្ត អាចអនុវត្តបានតែក្នុងករណីទីកន្លែង និងកម្មវិធីនានា ត្រូវបានកសាងឡើងសមស្រប ដើម្បីបង្កលក្ខណៈងាយស្រួលជារូបវន្ត និងព័ត៌មានតាមទម្រង់ដែលអាចប្រើប្រាស់បានដោយជនពិការ។

ការិយាល័យឧត្តមស្នងការ អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ធ្វើការបកប្រែសេចក្តីពន្យល់ទូទៅលេខ២ លើមាត្រា៩ នេះ ដោយសង្ឃឹមថា សេចក្តីពន្យល់នេះនឹងជួយដល់រាជរដ្ឋាភិបាលកម្ពុជា អង្គការសង្គមស៊ីវិល សហគ្រាសឯកជន ដៃគូអភិវឌ្ឍន៍ និងជនពិការខ្លួនឯង ឲ្យកាន់តែមានការយល់ដឹង ហើយទីបញ្ចប់ យកមកអនុវត្តទស្សនៈនៃការបង្កលក្ខណៈងាយស្រួល ដូចមានចែងក្នុងមាត្រា៩។ ជាមួយនឹងល្បឿនគួរឲ្យកត់សំគាល់ ដែលទីក្រុងភ្នំពេញមានការផ្លាស់ប្តូរមុខមាត់ ជា

មួយនឹងអាគារខ្ពស់ៗ សេចក្តីពន្យល់ទូទៅនេះ នៅមិនទាន់យឺតពេលនៅឡើយទេ។ គ្មានមន្ទិលសោះថា សេចក្តីពន្យល់ទូទៅនេះ នឹងបង្ហាញពីសារៈសំខាន់ក្នុងការធានាថាតម្រូវការឲ្យមានការបង្កលក្ខណៈងាយស្រួលដល់ជនពិការកម្ពុជា គឺត្រូវតែឆ្លុះបញ្ចាំងឲ្យបានត្រឹមត្រូវក្នុងការអភិវឌ្ឍន៍ប្រទេស ជាពិសេស ក្នុងការធ្វើផែនការទីក្រុងនាពេលអនាគត។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សកម្ពុជា

ខែមករា ឆ្នាំ២០១៥

# អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ

## មាត្រា៩ ៖ ការបង្កលក្ខណៈងាយស្រួល

១- ដើម្បីជួយជនពិការឱ្យរស់នៅដោយឯករាជ្យ និងចូលរួមយ៉ាងពេញលេញក្នុងគ្រប់ទិដ្ឋភាពនៃជីវិត រដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីធានាដល់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកផ្សេងទៀត ទទួលបាននូវបរិស្ថានជុំវិញខ្លួនមធ្យោបាយធ្វើដំណើរ ព័ត៌មាននិងទំនាក់ទំនង រួមទាំងប្រព័ន្ធនិងបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង គ្រឿងបរិក្ខារ និងសេវាកម្មផ្សេងទៀត ដែលបើក ឬផ្តល់ឱ្យប្រើប្រាស់ជាសាធារណៈ ទាំងនៅទីក្រុង ទាំងនៅតាមទីជនបទ។ ដោយត្រូវរួមបញ្ចូលនូវអត្តសញ្ញាណ និងការលុបបំបាត់ឧបសគ្គ និងរបាំងទាំងឡាយដល់ការទទួលបានសិទ្ធិទាំងនេះ វិធានការទាំងនេះត្រូវអនុវត្តចំពោះ៖

ក. អាគារ ផ្លូវថ្នល់ មធ្យោបាយធ្វើដំណើរ និងគ្រឿងបរិក្ខារក្នុងផ្ទះ និងក្រៅផ្ទះផ្សេងទៀត រួមទាំងសាលារៀន លំនៅដ្ឋាន គ្រឹះស្ថានសុខាភិបាល និងកន្លែងការងារ។

ខ. ព័ត៌មាន ទំនាក់ទំនង និងសេវាកម្មដទៃទៀត រួមទាំងសេវាកម្មអេឡិចត្រូនិច និងសេវាកម្មសង្គ្រោះបន្ទាន់។

២- រដ្ឋភាគី ត្រូវចាត់វិធានការសមស្របផងដែរដើម្បី៖

ក. តាក់តែង ប្រកាសឱ្យប្រើ និងតាមដានការអនុវត្តន៍គោលការណ៍ណែនាំ និងបទដ្ឋានអប្បបរមាសំរាប់ការទទួលបាននូវគ្រឿងបរិក្ខារ និងសេវាកម្មដែលបើក និងផ្តល់ឱ្យសាធារណជន។

ខ. ធានាថា អង្គភាពឯកជនដែលផ្តល់សេវាកម្ម និងគ្រឿងបរិក្ខារដែលបើក ឬផ្តល់ឱ្យសាធារណជន ត្រូវពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយពីការបង្កលក្ខណៈងាយស្រួលដល់ជនពិការ។

គ. ផ្តល់ការបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធ ពីបញ្ហាពាក់ព័ន្ធនឹងការបង្កលក្ខណៈងាយស្រួល ដែលជនពិការកំពុងជួបប្រទះ។

ឃ. ដាក់ស្លាកសញ្ញា ជាអក្សរស្ទាប និងជាទំរង់ងាយអាន ងាយយល់ នៅតាមអគារ និងទីកន្លែងសាធារណៈដទៃទៀត។

ង. ផ្តល់ទម្រង់នៃជំនួយផ្ទាល់ និងអន្តរការី រួមបញ្ចូល អ្នកនាំផ្លូវ អ្នកជំនាញអាន និងអ្នកបកប្រែភាសាសញ្ញាអាជីព ដើម្បីបង្កភាពងាយស្រួលដល់ការប្រើប្រាស់អគារ និងទីកន្លែងសាធារណៈផ្សេងទៀតបាន។

ច. លើកស្ទួយទំរង់នៃការជួយ និងការគាំពារសមស្របដទៃទៀតដល់ជនពិការ ដើម្បីធានាថា ពួកគេទទួលបានព័ត៌មាន។

ឆ. លើកស្ទួយជនពិការ ឱ្យទទួលបានប្រព័ន្ធ និងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងថ្មីៗ រួមទាំងអ៊ិនធឺណេតផង។

ជ. លើកស្ទួយការរចនា ការអភិវឌ្ឍន៍ផលិតកម្ម និងការចែកចាយប្រព័ន្ធ និងបច្ចេកវិទ្យាព័ត៌មានដែលអាចទទួលបាននៅដំណាក់ដំបូង ដូច្នេះប្រព័ន្ធនិងបច្ចេកវិទ្យាទាំងនេះ នឹងមានតម្លៃថោកល្មមអាចទទួលយកបាន។

# I. សេចក្តីផ្តើម

១. ការបង្កលក្ខណៈងាយស្រួលគឺជាបុរេលក្ខខណ្ឌសម្រាប់ឲ្យជនពិការរស់នៅដោយឯករាជ្យ និងចូលរួមដោយពេញលេញ និងដោយស្មើភាពគ្នានៅក្នុងសង្គម។ ដោយមិនទទួលបាននូវបរិស្ថានរូបវ័ន្ត មធ្យោបាយដឹកជញ្ជូន ព័ត៌មាននិងទំនាក់ទំនង រាប់ទាំងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង ព្រមទាំងសម្ភារៈបរិក្ខារ និងសេវាកម្មផ្សេងៗទៀត ដែលបើកចំហ និងផ្តល់ដល់សាធារណៈជនទូទៅនោះ ជនពិការនឹងមិនមានឱកាសស្មើគ្នាសម្រាប់ការចូលរួមក្នុងសង្គមរបស់គេរៀងខ្លួនៗបានឡើយ។ វាមិនមែនជាការចៃដន្យទេ ដែលការបង្កលក្ខណៈងាយស្រួលនេះ ក្លាយទៅជាគោលការណ៍មួយនៃគោលការណ៍នានា ដែលជាមូលដ្ឋាននៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ (មាត្រា៣(ច))។ ជាប្រវត្តិសាស្ត្រចលនារបស់ជនពិការបានអះអាងថា ការទទួលបាននូវបរិស្ថានរូបវ័ន្ត និងសេវាដឹកជញ្ជូនសាធារណៈសម្រាប់ជនពិការ គឺជាបុរេលក្ខខណ្ឌមួយដល់សេរីភាពនៃការដើរហើរដូចត្រូវបានធានាការពារនៅក្នុងមាត្រា១៣ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា១២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ ដូចគ្នានេះដែរ សិទ្ធិទទួលបានព័ត៌មាន និងទំនាក់ទំនងត្រូវបានឃើញថាជាបុរេលក្ខខណ្ឌមួយដល់សេរីភាពនៃការបញ្ចេញមតិ/យោបល់ ដូចត្រូវបានធានាការពារនៅក្នុងមាត្រា១៩ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងមាត្រា១៩ កថាខណ្ឌ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

២. មាត្រា២៥(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ចែងអំពីសិទ្ធិរបស់ពលរដ្ឋគ្រប់រូប ក្នុងការទទួលបានសិទ្ធិប្រើប្រាស់សេវាសាធារណៈ នៅក្នុងប្រទេសរបស់ខ្លួន ដោយឈរលើអត្ថន័យទូទៅនៃភាពស្មើគ្នា។ បទប្បញ្ញត្តិនៃមាត្រានេះ អាចដើរតួនាទីជាមូលដ្ឋានក្នុងការបញ្ចូលសិទ្ធិនៃការទទួលបាននេះ ទៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សស្នូលផ្សេងៗ។

៣. អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ធានាការពារជនគ្រប់រូបអំពីសិទ្ធិនៃការទទួលបានសិទ្ធិប្រើប្រាស់ទីកន្លែង ឬសេវាកម្មមួយដែលដាក់ឲ្យសាធារណជនទូទៅប្រើប្រាស់ ដូចជា សេវាដឹកជញ្ជូនតាមសណ្ឋាគារ ភោជនីយដ្ឋាន ហាងកាហ្វេ រោងល្ខោន និងសួនច្បារ (មាត្រា៥(ច))។ ដូច្នេះ ក្របខណ្ឌច្បាប់សិទ្ធិមនុស្សអន្តរជាតិបានបង្កើតករណីយុត្តិសាស្ត្រមួយ ក្នុងការពិនិត្យមើលអំពីសិទ្ធិនៃការទទួលបាននេះ ថាជាសិទ្ធិមួយតែឯង។ និយាយដោយពិតទៅ សម្រាប់សមាជិកមកពីក្រុមជាតិសាសន៍ ឬជាតិពន្ធុផ្សេងគ្នា ឧបសគ្គរារាំងដល់ការទទួលបានសិទ្ធិប្រើប្រាស់ដោយសេរីនូវទីកន្លែង ឬសេវាកម្មនានា ដែលបើកចំហដល់សាធារណជនទូទៅនោះ កើតចេញពីឥរិយាបថបុរេនិច្ឆ័យ និងការត្រៀមប្រើប្រាស់កម្លាំងក្នុងការទប់ស្កាត់នូវការទទួលបានសិទ្ធិប្រើប្រាស់ទីកន្លែងទាំងនោះ ដែលឃើញយ៉ាងច្បាស់ថា

អាចទទួលបានការប្រើប្រាស់នោះយ៉ាងជាក់ស្តែង។ ក៏ប៉ុន្តែ ជនពិការត្រូវប្រឈមមុខនឹងឧបសគ្គផ្នែកបច្ចេកទេស ផ្នែកបរិស្ថាន និងភាគច្រើនឧបសគ្គផ្នែកបរិស្ថាន ដែលបង្កើតឡើងដោយមនុស្ស ដូចជា ជណ្តើរនៅច្រកចេញ-ចូលអាគារ គ្មានជណ្តើរយោងក្នុងអាគារកំពស់ច្រើនជាន់ និងកង្វះខាតព័ត៌មានក្នុងទម្រង់ដែលជនពិការអាចទទួលយកបាន។ បរិស្ថានដែលបានបង្កើតឡើង តែងតែមានទំនាក់ទំនងទៅនឹងការអភិវឌ្ឍន៍សង្គម និងវប្បធម៌ ក៏ដូចជាទំនៀមទម្លាប់ ហេតុដូច្នេះ បរិស្ថានដែលបង្កើតឡើងដោយមនុស្ស គឺស្ថិតនៅក្រោមការត្រួតត្រាទាំងស្រុងរបស់សង្គម។ ឧបសគ្គសិប្បនិម្មិតទាំងនេះ ច្រើនកើតចេញពីកង្វះព័ត៌មាន និងជំនាញបច្ចេកទេស ជាជាងកើតចេញពីឆន្ទៈជាសម្បជញ្ញៈ ដើម្បីរារាំងជនពិការពីការទទួលបានសិទ្ធិប្រើប្រាស់នូវទីកន្លែង និងសេវាកម្មនានាដែលមានបំណងដាក់ឲ្យសាធារណជនប្រើប្រាស់ជាទូទៅនោះ។ ដើម្បីណែនាំឲ្យប្រើប្រាស់គោលនយោបាយ ដែលអនុញ្ញាតិឲ្យមានការបង្កលក្ខណៈងាយស្រួល កាន់តែប្រសើរសម្រាប់ជនពិការនោះ ការផ្លាស់ប្តូរឥរិយាបថចំពោះជនពិការ គឺជាការចាំបាច់ដើម្បីប្រយុទ្ធប្រឆាំងនឹងស្លាកស្នាមទុរយស និងការរើសអើង តាមរយៈកិច្ចខំប្រឹងប្រែងអប់រំបន្ត ការលើកកម្ពស់ការយល់ដឹង យុទ្ធនាការ និងទំនាក់ទំនងវប្បធម៌។

៤. កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ចែងយ៉ាងច្បាស់អំពីសិទ្ធិនៃការទទួលបាននេះថាជាផ្នែកមួយនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ការបង្កលក្ខណៈងាយស្រួលគួរត្រូវបានយល់ថា ជាការបញ្ជាក់ឡើងវិញអំពីពិការភាពជាក់លាក់ ឬជាទិដ្ឋភាពសង្គមអំពីសិទ្ធិនៃការទទួលបាននេះ។ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ បញ្ចូលការបង្កលក្ខណៈងាយស្រួល ថាជាគោលការណ៍មួយ ក្នុងចំណោមគោលការណ៍ជាមូលដ្ឋានចំបងៗនៃអនុសញ្ញានេះ - ជាបុរេលក្ខខណ្ឌដ៏សំខាន់បំផុតមួយ សម្រាប់ជនពិការក្នុងការទទួលបានដោយប្រសិទ្ធភាព និងដោយស្មើភាពគ្នានូវសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ចសង្គមកិច្ច និងសិទ្ធិវប្បធម៌ផ្សេងៗគ្នា។ ការបង្កលក្ខណៈងាយស្រួល គួរត្រូវបានគិតគូរនៅក្នុងបរិបទនៃសមភាព និងការមិនរើសអើង។ លើសពីនេះ ការបង្កលក្ខណៈងាយស្រួល ក៏អាចត្រូវបានយល់ថា ជាផ្នែកមួយនៃការផ្តល់អំណាចក្នុងសង្គមផងដែរ និងអាចត្រូវមើលឃើញថាជាផ្នែកទាំងស្រុងមួយ នៃកម្មវិធីអភិវឌ្ឍន៍ប្រកបដោយចីរភាព។

៥. ខណៈដែលពលរដ្ឋ និងអង្គការផ្សេងគ្នាមានការយល់ដឹងខុសៗគ្នា អំពីអត្ថន័យនៃពាក្យបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង(ICT) ក៏ពួកគេទាំងអស់គ្នាទទួលស្គាល់ថាបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងជាពាក្យបណ្តុំមួយដែលរួមបញ្ចូលនូវគ្រប់ឧបករណ៍ ឬកម្មវិធីព័ត៌មាននិងទំនាក់ទំនង ព្រមទាំងខ្លឹមសាររបស់វាផង។ ការផ្តល់និយមន័យបែបនេះ បានបញ្ចូលនូវការទទួលបានវិសាលភាពយ៉ាងទូលាយនៃបច្ចេកវិទ្យា ដូចជា វិទ្យុ ទូរទស្សន៍ផ្កាយរណប ទូរសព្ទចល័ត ទូរសព្ទប្រើខ្សែ កុំព្យូទ័រ បណ្តាញផ្នែករឹង និងផ្នែកទន់ សារៈសំខាន់នៃបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងស្ថិតនៅលើសមត្ថភាពដើម្បីបើកសេវាជាច្រើនប្រភេទ សេវាផ្ទេរដែលមានស្រាប់ និងបង្កើតនូវតម្រូវការធំធេងថែមទៀត ដល់ការទទួលបានព័ត៌មាន និងចំណេះដឹង ជាពិសេស ក្នុងចំណោមប្រជាជនដែលមិនទទួលបានសេវាគ្រប់គ្រាន់ និងប្រជាជនដែលមិនត្រូវបានគេដាក់បញ្ចូលក្នុងការផ្តល់សេវាទាំងនោះដូចជាជនពិការជាដើម។ មាត្រា១២ នៃបទប្បញ្ញត្តិទូរគមនាគមន៍អន្តរជាតិ(ក្រុងឌូបៃ ឆ្នាំ២០១២) ចែងអំពីសិទ្ធិជនពិការ ក្នុងការទទួលបានសេវាទូរគមនាគមន៍អន្តរជាតិ ដោយពិចារណាទៅលើអនុសាសន៍នានា របស់សហជីពទូរគមនាគមន៍អន្តរជាតិដែលពាក់ព័ន្ធ។ បទប្បញ្ញត្តិនៃមាត្រានេះ អាចដើរតួនាទីជាមូលដ្ឋានមួយដើម្បីពង្រឹងក្របខណ្ឌច្បាប់ជាតិរបស់រដ្ឋភាគី។

៦. ក្នុងសេចក្តីពន្យល់ទូទៅលេខ៥(១៩៩៤) គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានរំលឹកឡើងវិញអំពីករណីយកិច្ចរបស់រដ្ឋភាគី ក្នុងការអនុវត្តវិធានស្តង់ដាររបស់អង្គការសហប្រជាជាតិស្តីពីឱកាសស្មើភាពគ្នាសម្រាប់ជនពិការ។ វិធានស្តង់ដារនេះ ក៏មានរំលេចនូវសារៈសំខាន់នៃការបង្កលក្ខណៈងាយស្រួលដល់បរិស្ថានរូបវ័ន្ត ការដឹកជញ្ជូន ព័ត៌មាននិងទំនាក់ទំនងសម្រាប់ការធ្វើឲ្យមានឱកាសស្មើភាពគ្នាដល់ជនពិការ។ ទស្សនទាននេះ ត្រូវបានចែងនៅក្នុងវិធានទី៥ ដែលក្នុងនោះ ការបង្កលក្ខណៈងាយស្រួលចំពោះបរិស្ថានរូបវ័ន្ត ព័ត៌មាននិងទំនាក់ទំនងត្រូវបានកំណត់ទិសដៅជាវិស័យសំរាប់សកម្មភាពអាទិភាព សំរាប់រដ្ឋ។ សារៈសំខាន់នៃការបង្កលក្ខណៈងាយស្រួលនេះ ក៏អាចត្រូវបានស្រង់ចេញពីសេចក្តីពន្យល់ទូទៅលេខ១៤(២០០០) របស់គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (កថាខណ្ឌទី១២)។ ក្នុងសេចក្តីពន្យល់ទូទៅលេខ៩(២០០៦) ស្តីពីសិទ្ធិកុមារពិការ គណៈកម្មាធិការស្តីពីសិទ្ធិកុមារ បានសង្កត់ធ្ងន់អំពីការមិនបង្កលក្ខណៈងាយស្រួល នៃមធ្យោបាយដឹកជញ្ជូនសាធារណៈ និងបរិក្ខារដទៃទៀត រាប់ទាំងសំណង់អគាររដ្ឋាភិបាល កន្លែងលក់ទំនិញ និងទីកន្លែងកំសាន្តនានាផងនោះ គឺជាកត្តាចម្បងក្នុងការមិនយកចិត្តទុក និងការផាត់កុមារពិការចេញ ហើយជាក់ស្តែងណាស់ អនុគ្រោះដល់ការរារាំងនូវការទទួលបានសេវានានា រួម

ទាំងសេវាសុខភាព និងអប់រំផង។ សារៈសំខាន់នៃការបង្កលក្ខណៈងាយស្រួល ត្រូវបានបញ្ជាក់ឡើងវិញដោយគណៈកម្មាធិការនេះ នៅក្នុងសេចក្តីពន្យល់ទូទៅរបស់ខ្លួនលេខ១៧(២០១៣) ស្តីពីសិទ្ធិកុមារក្នុងការទទួលបានការសម្រាក ការលំហែ ការលេងសប្បាយ សកម្មភាពកំសាន្តផ្សេងៗ ជីវិតវប្បធម៌ និងសិល្បៈ (មាត្រា៣១)។

៧. *របាយការណ៍ពិភពលោកស្តីពីពិការភាព* (២០១១) ដែលបោះផ្សាយដោយអង្គការសុខភាពពិភពលោក និងធនាគារពិភពលោក ក្នុងក្របខណ្ឌនៃការពិគ្រោះយោបល់ដ៏ធំបំផុតមិនធ្លាប់មាន ដោយមានការចូលរួមយ៉ាងសកម្មពីអ្នកវិជ្ជាជីវៈរាប់រយនាក់ក្នុងវិស័យពិការភាព បានសង្កត់ធ្ងន់ថា បរិស្ថានដែលបានបង្កើតឡើង ប្រព័ន្ធដឹកជញ្ជូន ព្រមទាំងព័ត៌មាននិងទំនាក់ទំនង ច្រើនតែមិនបានបង្កលក្ខណៈងាយស្រួលដល់ជនពិការទេ (*របាយការណ៍ពិភពលោកស្តីពីពិការភាព៖ អត្ថបទសង្ខេប* ទំព័រទី១០)។ ជនពិការត្រូវបានរារាំងពីការទទួលបានសិទ្ធិជាមូលដ្ឋានមួយចំនួនរបស់ខ្លួន ដូចជាសិទ្ធិស្វែងរកការងារ ឬសិទ្ធិទទួលបានសេវាថែទាំសុខភាពជាដើម ដោយសារតែកង្វះការដឹកជញ្ជូន ដែលជនពិការអាចប្រើប្រាស់បាន។ កំរិតនៃការអនុវត្តច្បាប់ស្តីពីការបង្កលក្ខណៈងាយស្រួលនៅមានកម្រិតទាបនៅឡើយនៅតាមបណ្តាប្រទេសជាច្រើន ហើយជនពិការ ជារឿយៗត្រូវបានបដិសេធនូវសិទ្ធិសេរីភាពនៃការបញ្ចេញមតិ ដោយសារតែព័ត៌មាននិងទំនាក់ទំនងមិនបង្កលក្ខណៈ

ងាយស្រួលដល់ពួកគេ។ សូម្បីតែនៅក្នុងប្រទេសមួយចំនួន ដែលមានសេវាបកប្រែភាសាសញ្ញាសម្រាប់ជនពិការគថ្លង់ ក៏ចំនួនអ្នកបកប្រែដែលមានគុណសម្បត្តិគ្រប់គ្រាន់ នៅមានកម្រិតទាបនៅឡើយ ហើយដោយសារតែអ្នកបកប្រែទាំងនោះ ត្រូវធ្វើដំណើរដោយខ្លួនឯងទៅរកអតិថិជនរបស់ខ្លួនផងនោះ ធ្វើឲ្យអ្នកបកប្រែទាំងនោះមានតម្លៃថ្លៃពេក មិនអាចបំពេញតាមតម្រូវការដែលកំពុងតែមានការកើនឡើងបាននោះទេ។ ជនពិការបញ្ញា និងចិត្តសង្គមរួមជាមួយជនពិការភ្នែក-ថ្លង់ផងនោះ ប្រឈមមុខនឹងរបាំងនានាក្នុងការប៉ុនប៉ងចង់ទទួលបានព័ត៌មាននិងទំនាក់ទំនង ដោយសារតែកង្វះទម្រង់ងាយស្រួលអាន និងកង្វះខាតមធ្យោបាយជំនួស និងចំនួនបន្ថែម។ ពួកគេក៏ប្រឈមមុខនឹងរបាំងនានា នៅពេលប៉ុនប៉ងដើម្បីទទួលបានសេវាទាំងនោះផងដែរដោយសារតែបុរេនិច្ច័យ និងកង្វះការបណ្តុះបណ្តាលឲ្យបានគ្រប់គ្រាន់ ដល់បុគ្គលិកដែលផ្តល់សេវាទាំងនោះ។

៨. របាយការណ៍ស្តីពីការធ្វើទូរទស្សន៍ឲ្យអាចទស្សនាបានទាំងអស់គ្នា ដែលសរសេរដោយសហជីពទូរគមនាគមន៍អន្តរជាតិក្រោមកិច្ចសហការជាមួយគម្រោងផ្តួចផ្តើមសកល សម្រាប់បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងដែលត្រូវដាក់បញ្ចូល(G3ICT) គូសបញ្ជាក់ថា ចំនួនសមាមាត្រដ៏ធំសម្បើមមួយនៃប្រជាជនមួយពាន់លាននាក់ ដែលរស់នៅក្នុងទម្រង់ណាមួយនៃពិការភាពនោះ មិន

អាចទទួលបានខ្លឹមសារជាចក្ខុទស្សន៍ សោតទស្សន៍ឡើយ។ កង្វះខាតការទទួលបាននេះ ផ្តើមចេញពីការមិនទទួលបានខ្លឹមសារព័ត៌មាន និង/ឬឧបករណ៍ចាំបាច់នានាដែលជួយពួកគាត់ឲ្យទទួលបានសេវាទាំងនោះ។

៩.ការបង្កលក្ខណៈងាយស្រួលត្រូវបានទទួលស្គាល់ដោយសហគមន៍ICTដែលមានឥទ្ធិពលតាំងពីដំណាក់កាលដំបូងនៃសន្និសីទកំពូលពិភពលោកស្តីពីសង្គមព័ត៌មានវិទ្យាកាលពីឆ្នាំ២០០៣។ តាមរយៈការណែនាំ និងការជំរុញដោយសហគមន៍ជនពិការទស្សនទាននេះ ត្រូវបានដាក់បញ្ចូលទៅក្នុងសេចក្តីប្រកាសអំពីគោលការណ៍របស់សន្និសីទកំពូលនេះ ដែលក្នុងនោះ កថាខណ្ឌទី២៥ ចែងថា "២៥-ការចែករំលែកនិងការពង្រឹងចំណេះដឹងសកលសម្រាប់ការអភិវឌ្ឍន៍ អាចត្រូវបានលើកកំពស់ តាមរយៈការដកចេញនូវរបាំងនានាដែលរារាំងដល់ការទទួលបានដោយស្មើភាពគ្នានូវព័ត៌មានអំពីសកម្មភាពសេដ្ឋកិច្ច សង្គម នយោបាយ សុខភាព វប្បធម៌ អប់រំ និងវិទ្យាសាស្ត្រ និងតាមរយៈការសម្រួលដល់ការទទួលបានព័ត៌មានក្នុងវិស័យសាធារណៈ រួមទាំងការរចនាប្លង់ជាសកល និងការប្រើប្រាស់បច្ចេកវិទ្យាជំនួយ"។

១០. គណៈកម្មាធិការស្តីពីសិទ្ធិជនពិការ បានចាត់ទុកការបង្កលក្ខណៈងាយស្រួល ថាជាបញ្ហាដ៏សំខាន់មួយក្នុងចំណោមបញ្ហាសំខាន់ៗជាច្រើន នៅរៀងរាល់កិច្ចសន្ទនាទាំងដប់ ដែលខ្លួនបានរៀបចំឡើង រហូតដល់ដំណើរការព្រាងនៃសេចក្តីពន្យល់ទូទៅនេះជាមួយរដ្ឋភាគីដើម្បីពិចារណាអំពីរបាយការណ៍ដំបូងរបស់រដ្ឋ។ សេចក្តីសង្កេតសន្និដ្ឋានសុទ្ធតែមានអនុសាសន៍ទាក់ទងនឹងការបង្កលក្ខណៈងាយស្រួលនេះ។ បញ្ហាប្រឈមសាមញ្ញមួយ គឺកង្វះខាតយន្តការឃ្លាំមើលគ្រប់គ្រាន់ ដើម្បីធានាឲ្យមានការអនុវត្តជាក់ស្តែងនូវការបង្កលក្ខណៈងាយស្រួលតែមួយដូចគ្នា និងច្បាប់ពាក់ព័ន្ធ។ នៅក្នុងរដ្ឋភាគីមួយចំនួន ការឃ្លាំមើលគឺជាការទទួលខុសត្រូវរបស់អាជ្ញាធរមូលដ្ឋាន ដែលខ្វះខាតចំណេះដឹងបច្ចេកទេស និងខ្វះខាតធនធានមនុស្ស និងសម្ភារៈសម្រាប់ធានាដល់ការអនុវត្តឲ្យមានប្រសិទ្ធភាព។ បញ្ហាប្រឈមសាមញ្ញមួយទៀត គឺកង្វះខាតការបណ្តុះបណ្តាល ដែលត្រូវផ្តល់ទៅឲ្យដៃគូពាក់ព័ន្ធ និងការចូលរួមមិនគ្រប់គ្រាន់របស់ជនពិការ និងអង្គការតំណាងជនពិការ នៅក្នុងដំណើរការ នៃការធានាឲ្យទទួលបាន នូវការប្រើប្រាស់បរិស្ថានរូបវ័ន្ត ការដឹកជញ្ជូន ព័ត៌មាននិងទំនាក់ទំនង។

១១. គណៈកម្មាធិការស្តីពីសិទ្ធិជនពិការ ក៏បានលើកឡើងពីបញ្ហានៃការបង្កលក្ខណៈងាយស្រួលនេះ នៅក្នុងករណីយុត្តិសាស្ត្ររបស់ខ្លួនដែរ។ ក្នុងរឿងក្តី Szilvia Nyusti, Péter Takács និងTamás Fazekas ទល់នឹងប្រទេសហុងគ្រី (បណ្តឹងលេខ ១/២០១០ ទស្សនៈត្រូវបានអនុម័តកាលពីថ្ងៃទី១៦ ខែមេសា ឆ្នាំ ២០១៣) គណៈកម្មាធិការយល់ឃើញថា សេវាកម្មទាំងអស់ដែលបើកចំហ ឬផ្តល់ដល់សាធារណជនទូទៅ ត្រូវតែអាចប្រើប្រាស់បានដោយជនពិការ ស្របតាមបញ្ញត្តិនៃមាត្រា៩ នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ។ មានការអំពាវនាវឲ្យរដ្ឋភាគីត្រូវធានាថា ជនពិការភ្នែកអាចទទួលបានការប្រើប្រាស់ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ATM ។ គណៈកម្មាធិការបានផ្តល់អនុសាសន៍ ក្នុងចំណោមបញ្ហាផ្សេងៗទៀតថា រដ្ឋភាគីគួរបង្កើតស្តង់ដារអប្បបរមាសម្រាប់ការបង្កលក្ខណៈងាយស្រួលនៃសេវាធនាគារ ដែលផ្តល់ដោយស្ថាប័នហិរញ្ញវត្ថុឯកជន សម្រាប់អ្នកដែលមានការខូចខាតចក្ខុទស្សន៍ និងមានការអន់ថយប្រភេទផ្សេងទៀត" "បង្កើតក្របខណ្ឌច្បាប់ ដោយមានកាលវិភាគច្បាស់លាស់ អាចអនុវត្តបាន និងមានពេលវេលាកំណត់សម្រាប់ការតាមដានឃ្លាំមើល និងការវាយតំលៃអំពីការកែប្រែ និងការកែតម្រូវជាបន្តបន្ទាប់ ដោយស្ថាប័នហិរញ្ញវត្ថុឯកជនដែលសេវាធនាគាររបស់ខ្លួនកាលពីមុនមិនអាចប្រើប្រាស់បានដោយជនពិការ

ទៅជាសេវាមួយដែលអាចប្រើប្រាស់បានដោយជនពិការវិញ" ព្រមទាំង "ធានាថារាល់ម៉ាស៊ីនដកប្រាក់ដោយស្វ័យប្រវត្តិដែលធនាគារទិញថ្មីៗ និងសេវាធនាគារផ្សេងៗទៀត អាចប្រើប្រាស់បានយ៉ាងពេញលេញដោយជនពិការ (វាក្យខណ្ឌទី១០.២(ក))។

១២. ដោយសារតែករណីយុត្តិសាស្ត្រទាំងនេះ និងការពិតដែលថា ការបង្កលក្ខណៈងាយស្រួល គឺពិតជាបុរេលក្ខខណ្ឌដ៏សំខាន់បំផុតមួយសម្រាប់ជនពិការ ចូលរួមឲ្យបានពេញលេញ និងដោយស្មើភាពគ្នាក្នុងសង្គម និងទទួលបានសិទ្ធិមនុស្ស និងសេរីភាពជាសារវ័ន្តទាំងអស់របស់ពួកគេ ប្រកបដោយប្រសិទ្ធភាពនោះ គណៈកម្មាធិការយល់ឃើញថា វាជាការចាំបាច់ត្រូវអនុម័តសេចក្ដីពន្យល់ទូទៅមួយ ទៅលើមាត្រា៩ នៃអនុសញ្ញានេះ ស្ដីពីការបង្កលក្ខណៈងាយស្រួល ស្របតាមវិធាននីតិវិធីរបស់ខ្លួន និងការអនុវត្តកន្លងមករបស់ស្ថាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស។

## II. ខ្លឹមសារគតិយុត្តិ

១៣. មាត្រា៩ នៃអនុសញ្ញាស្តីពីសិទ្ធិជនពិការ ចែងថា "ដើម្បីអាចឲ្យជនពិការរស់នៅដោយឯករាជ្យនិងចូលរួមយ៉ាងពេញលេញក្នុងគ្រប់ទិដ្ឋភាពនៃជីវិត រដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដើម្បីធានាដល់ជនពិការ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ឲ្យទទួលបាននូវការប្រើប្រាស់បរិស្ថានរូបវន្ត មធ្យោបាយធ្វើដំណើរ ព័ត៌មាននិងទំនាក់ទំនង ព្រមទាំងប្រព័ន្ធ និងបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង គ្រឿងសម្រួលផ្សេងៗ និងសេវាកម្មដទៃទៀត ដែលបើកចំហ ឬត្រូវផ្តល់ជូនជាសាធារណៈ ទាំងនៅទីក្រុងទាំងនៅជនបទ។" ប្រការសំខាន់គឺថា ការបង្កលក្ខណៈងាយស្រួលត្រូវលើកមកដោះស្រាយ នៅគ្រប់ជ្រុងនៃភាពស្មុគស្មាញរបស់វាដែលនៅជុំវិញបរិស្ថានរូបវន្ត មធ្យោបាយធ្វើដំណើរ ព័ត៌មាន និងទំនាក់ទំនង និងសេវាកម្មផ្សេងៗ។ ការយកចិត្តទុកដាក់លែងផ្តោតទៅលើបុគ្គលិកលក្ខណៈគតិយុត្តិ និងចរិកលក្ខណៈឯកជន ឬសាធារណៈរបស់ម្ចាស់អគារ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន យានជំនិះ ព័ត៌មាននិងទំនាក់ទំនង និងសេវាកម្មផ្សេងៗទៀតហើយ។ ដរាបណាទំនិញ ផលិតផល និងសេវាកម្មទាំងឡាយដែលត្រូវបើកចំហ និងត្រូវផ្តល់ជូនសាធារណជន ដរាបនោះរបស់ទាំងនេះត្រូវ

តែអាចប្រើប្រាស់បានដោយមនុស្សទាំងអស់គ្នាដោយមិនគិតថាតើរបស់ទាំងនេះមានម្ចាស់ និង/ឬផ្តល់ឲ្យដោយអាជ្ញាធរសាធារណៈ ឬសហគ្រាសឯកជននោះទេ។ ជនពិការគួរទទួលបានដោយស្មើភាពគ្នាចំពោះទំនិញ ផលិតផល និងសេវាកម្មទាំងអស់ដែលបើកចំហ ឬផ្តល់ដល់សាធារណជនក្នុងលក្ខណៈមួយដែលធានាឲ្យការទទួលបានមានប្រសិទ្ធភាព និងដោយស្មើភាព ព្រមទាំងគោរពសេចក្តីថ្លៃថ្នូររបស់ពួកគេ។ វិធីសាស្ត្រនេះ ផ្តើមចេញពីការហាមឃាត់ប្រឆាំងនឹងការរើសអើង ការបដិសេធក្នុងការទទួលបាន ត្រូវចាត់ទុកជាការបង្កើតឲ្យមានអំពើនៃការរើសអើង ដោយមិនគិតថាតើជនប្រព្រឹត្តនោះ ជាអង្គភាពសាធារណៈ ឬឯកជនឡើយ។ ការបង្កលក្ខណៈងាយស្រួល គប្បីផ្តល់ដល់ជនពិការគ្រប់រូបដោយមិនគិតអំពីប្រភេទនៃភាពអន់ខ្សោយ ដោយមិនមានការបែងចែកប្រភេទណាមួយ មានជាអាទិ៍ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃទៀត ស្ថានភាពសង្គម ឬផ្លូវច្បាប់ យេនឌ័រ ឬអាយុឡើយ។ ការបង្កលក្ខណៈងាយស្រួល គួរពិចារណាជាពិសេសអំពីទស្សនៈយេនឌ័រ និងអាយុរបស់ជនពិការ។

១៤. មាត្រា៩ នៃអនុសញ្ញានេះចែងយ៉ាងច្បាស់ថា ការបង្កលក្ខណៈងាយស្រួល គឺជាបុរេលក្ខខណ្ឌដើម្បីជួយជនពិការឲ្យរស់នៅដោយឯករាជ្យ និងចូលរួមយ៉ាងពេញលេញ និងស្មើភាពគ្នាក្នុងសង្គម ហើយទទួលបានសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទាំងអស់ ដោយគ្មានការរឹតត្បឹត ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។ មាត្រា៩ មានឫសគល់នៅក្នុងសិទ្ធិមនុស្សដែលមានស្រាប់ ដូចជាក្នុងមាត្រា២៥(គ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អំពីសិទ្ធិទទួលបានសេវាសាធារណៈដោយស្មើភាពគ្នា និងក្នុងមាត្រា៥(ច) នៃអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ អំពីសិទ្ធិចេញចូលទីកន្លែង ឬសេវាកម្មសម្រាប់ការប្រើប្រាស់ជាសាធារណៈ។ នៅពេលដែលសន្ធិសញ្ញាសិទ្ធិមនុស្សស្នូលទាំងពីរនេះ ត្រូវបានអនុម័ត ប្រព័ន្ធអ៊ីនធើណែតដែលបានផ្លាស់ប្តូរពិភពលោកគួរឲ្យកត់សំគាល់នេះ នៅមិនទាន់មាននៅឡើយទេ។ ដូច្នេះ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិជនពិការ គឺជាសន្ធិសញ្ញាសិទ្ធិមនុស្សដំបូងគេក្នុងសតវត្សទី២១ ដែលលើកឡើងអំពីសិទ្ធិទទួលបានបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងនេះ គឺមិនមែនបង្កើតសិទ្ធិថ្មីសម្រាប់តែជនពិការនោះទេ។ លើសពីនេះទៀត សញ្ញាណនៃសមភាពក្នុងច្បាប់អន្តរជាតិ មានការផ្លាស់ប្តូរ ក្នុងរយៈពេលប៉ុន្មានទសវត្សចុងក្រោយនេះ។ ការផ្លាស់ប្តូរជាទស្សនទានពីសមភាពជាផ្លូវការ ទៅជាសម

ភាពជាសារធាតុ មានផលប៉ះពាល់ទៅលើភារកិច្ចរបស់រដ្ឋភាគី។ កាតព្វកិច្ចផ្តល់ការបង្កលក្ខណៈងាយស្រួល គឺជាផ្នែកដ៏សំខាន់មួយនៃភារកិច្ចថ្មីនេះ ដើម្បីគោរព ការពារ និងបំពេញសិទ្ធិសមភាព។ ដូច្នេះ ការបង្កលក្ខណៈងាយស្រួលគួរត្រូវបានពិចារណានៅក្នុងបរិបទនៃសិទ្ធិទទួលបាន ដែលត្រូវបានមើលឃើញថាជាទស្សនៈវិស័យជាក់លាក់អំពីពិការភាព។ សិទ្ធិទទួលបានសម្រាប់ជនពិការត្រូវបានធានាតាមរយៈការអនុវត្តដ៏តឹងរ៉ឹងនៃស្តង់ដារការបង្កលក្ខណៈងាយស្រួល។ ឧបសគ្គទាំងឡាយដែលមាននៅក្នុងរបស់របរប្រើប្រាស់សម្ភារៈបរិក្ខារ ទំនិញ និងសេវាកម្មដែលមានបំណងដាក់ឲ្យសាធារណៈជនប្រើប្រាស់ ឬបើកចំហរដល់សាធារណជន ត្រូវតែលុបបំបាត់ជាបណ្តើរៗ ជាលក្ខណៈប្រព័ន្ធ និងកាន់តែសំខាន់នោះគឺតាមរយៈការឃ្លាំមើលមិនឈប់ឈរ ដោយឈរលើគោលបំណងសម្រេចឲ្យបានពេញលេញនូវការបង្កលក្ខណៈងាយស្រួល។

**១៥**. ការអនុវត្តដ៏តឹងរ៉ឹងនៃការរចនាប្លង់ជាសកលដែលអាចប្រើប្រាស់បានដោយបុគ្គលគ្រប់រូប សម្រាប់គ្រប់ទំនិញ ផលិតផលសម្ភារៈបរិក្ខារ បច្ចេកវិទ្យា និងសេវាកម្មទាំងអស់ គួរធានាឲ្យមានការទទួលបានដោយពេញលេញ ដោយស្មើភាព និងដោយគ្មានការរឹតត្បិតដល់អ្នកប្រើប្រាស់ទាំងអស់ ដោយរាប់បញ្ចូលទាំងជនពិការផង តាមមធ្យោបាយមួយដែលយកចិត្តទុកដាក់ពេញលេញ

ដល់សេចក្តីថ្លៃថ្នូរ និងភាពចម្រុះដែលមានពីកំណើតរបស់ពួកគេ។ បញ្ហានេះ គួររួមចំណែកដល់ការបង្កើតសង្វាក់នៃការបន្លាស់ទីដោយគ្មានការរឹតត្បិតមួយ សម្រាប់បុគ្គលម្នាក់ៗ ពីកន្លែងមួយទៅកន្លែងមួយ រួមទាំងការបន្លាស់ទីនៅក្នុងទីតាំងជាក់លាក់មួយចំនួនដោយគ្មានការរារាំង។ ជនពិការ និងអ្នកប្រើប្រាស់ដទៃទៀត គួរតែអាចផ្លាស់ទីបាននៅតាមផ្លូវដោយមិនមានការរារាំង អាចប្រើប្រាស់យានជំនិះទាំងឡាយដែលមានបាតទាប សិទ្ធិទទួលព័ត៌មាននិងទំនាក់ទំនងនិងអាចចូល-ចូលនិងបម្លាស់ទីបាននៅក្នុងអាគារដែលត្រូវបានរចនាតាមប្លង់ជាសកល ដោយប្រើប្រាស់គ្រឿងជំនួយបច្ចេកទេស និងជំនួយរស់រវើក តាមការចាំបាច់។ ការអនុវត្តការរចនាប្លង់ជាសកល មិនអាចលុបបំបាត់តម្រូវការប្រើគ្រឿងជំនួយបច្ចេកទេសដោយឯកឯងនោះទេ។ ការអនុវត្តទៅលើអាគារមួយចាប់តាំងពីដំណាក់កាលរចនាប្លង់ដំបូងមក នឹងជួយឲ្យការសាងសង់ចំណាយលុយមិនសូវច្រើន៖ ការធ្វើឲ្យអាគារអាចប្រើប្រាស់បានដោយជនពិការតាំងពីដើមទីទៅ អាចមិនបង្កើនចំណាយសរុបក្នុងការសាងសង់នោះទេ ក្នុងករណីជាច្រើន ឬក៏ចំណាយអាចកើនឡើងតិចតួចបំផុតក្នុងករណីខ្លះ។ ផ្ទុយទៅវិញ ចំណាយសម្រាប់ការសម្របអាគារ ដើម្បីធ្វើឲ្យជនពិការអាចប្រើប្រាស់បាននៅពេល

ក្រោយៗមកទៀត អាចមានចំនួនច្រើនបន្ថែមទៀតក្នុងករណីមួយចំនួន ជាពិសេស នៅតាមអាគារដែលមានលក្ខណៈប្រវត្តិសាស្ត្រមួយចំនួន។ ការអនុវត្តដំបូងនៃការរចនាប្លង់ជាសកល អាចមានលក្ខណៈសន្សំសំចៃច្រើនជាង ក៏ប៉ុន្តែចំណាយជាសក្តានុពលក្នុងការដករបាំងចេញនៅពេលក្រោយមកទៀត មិនអាចយកមកប្រើជាលេស ដើម្បីគេចវេសពីការបំពេញកាតព្វកិច្ច ក្នុងការដកចេញនូវរបាំងនានា ដើម្បីសម្រេចឲ្យបានការបង្កលក្ខណៈងាយស្រួលជាបន្តបន្ទាប់នោះឡើយ។ ការបង្កលក្ខណៈងាយស្រួល សម្រាប់ព័ត៌មាននិងទំនាក់ទំនង រួមទាំង បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង (ICT)ផងនោះ ក៏គួរសម្រេចឲ្យបានតាំងពីដើមទីទៅដែរពីព្រោះថាការសម្របតាម នៅពេលក្រោយៗទៀត ទៅលើអ៊ីនធើណែត និងបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងនេះ អាចបង្កើនការចំណាយ។ ដូច្នេះ ការតម្រូវបញ្ចូលកម្មវិធីដែលអាចប្រើប្រាស់បានដោយជនពិការ នៃបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង តាំងពីដំណាក់កាលដំបូងនៃការរចនាប្លង់ ព្រមទាំងការផលិតតាំងពីដំណាក់កាលដំបូងបំផុតនៃការរចនាប្លង់ និងការសាងសង់នោះ គឺមានលក្ខណៈសន្សំសំចៃជាង។

**១៦.** ការអនុវត្តការរចនាប្លង់ជាសកលនេះ ធ្វើឲ្យមនុស្សទាំងអស់អាចប្រាស្រ័យនៅបានក្នុងសង្គម គឺមិនមែនសម្រាប់តែជនពិការនោះទេ។ ប្រការសំខាន់ផងដែរនោះ គឺមាត្រា៩ ដាក់កំហិតយ៉ាងច្បាស់ទៅលើរដ្ឋភាគី នូវភារកិច្ចធានាឲ្យមានការបង្កលក្ខណៈងាយស្រួលនេះ ទាំងនៅតំបន់ទីក្រុង និងតំបន់ជនបទ។ ភស្តុតាងបានបង្ហាញថា ការបង្កលក្ខណៈងាយស្រួល ជាធម្មតាច្រើនមានភាពល្អប្រសើរនៅតាមទីក្រុងធំៗ ជាងតាមតំបន់ដាច់ស្រយាល តំបន់ជនបទដែលមិនសូវមានការអភិវឌ្ឍន៍ សូម្បីតែការធ្វើនគរូបនីយកម្មដ៏ធំទូលាយ ជួនកាលអាចបង្កើតជារបាំងថ្មីៗបន្ថែមទៀត ដែលរារាំងដល់ការទទួលបានសម្រាប់ជនពិការ ជាពិសេស ចំពោះបរិស្ថានដែលត្រូវបានបង្កើតឡើង ការដឹកជញ្ជូន និងសេវាកម្មនានា ក៏ដូចជាសេវាទំនាក់ទំនងព័ត៌មានដែលកាន់តែទំនើប នៅក្នុងតំបន់ទីក្រុងដែលមានមនុស្សកកកុញ និងមមាញឹកខ្លាំង។ ទាំងនៅតំបន់ទីក្រុង និងតំបន់ជនបទគួរបង្កលក្ខណៈងាយស្រួលដល់ជនពិការ ឲ្យទទួលបានការប្រើប្រាស់ទីតាំងធម្មជាតិ និងបេតិកភណ្ឌនៃបរិស្ថានរូបវន្ត ដែលសាធារណជនទូទៅអាចចេញ-ចូល និងទទួលបានភាពរីករាយ។

**១៧.** មាត្រា៩ កថាខណ្ឌទី១ តម្រូវឲ្យរដ្ឋភាគីត្រូវកំណត់អត្តសញ្ញាណ និងលុបបំបាត់ឧបសគ្គ និងរបាំងនានាដែលរារាំងការបង្កលក្ខណៈងាយស្រួលដល់ មានដូចជា៖

(ក). អាគារ ផ្លូវថ្នល់ មធ្យោបាយដឹកជញ្ជូន និងគ្រឿងសម្រួលក្នុងផ្ទះ និងក្រៅផ្ទះផ្សេងទៀត រួមទាំងសាលារៀន លំនៅដ្ឋាន គ្រឹះស្ថានសុខាភិបាល និងកន្លែងធ្វើការ។

(ខ). ព័ត៌មាន ទំនាក់ទំនង និងសេវាកម្មដទៃទៀត រួមទាំងសេវាកម្មអេឡិចត្រូនិច និងសេវាកម្មសង្គ្រោះបន្ទាន់ ការលើកឡើងខាងលើអំពី "គ្រឿងសម្រួលក្នុងផ្ទះ និងក្រៅផ្ទះផ្សេងទៀត" គួររួមបញ្ចូលសម្ភារៈបរិក្ខាររបស់ទីភ្នាក់ងារអនុវត្តច្បាប់ តុលាការ និងពន្ធនាគារ ស្ថាប័នសង្គម កន្លែងអន្តរកម្មសង្គម ទីកន្លែងកំសាន្ត គ្រឹះស្ថានសកម្មភាពវប្បធម៌ សកម្មភាពសាសនា សកម្មភាពនយោបាយ និងសកម្មភាពកីឡា ព្រមទាំងកន្លែងលក់ទំនិញជាដើម។ "សេវាកម្មដទៃទៀត" គួររួមបញ្ចូលបរិក្ខារប្រៃសណីយ៍ ធនាគារ ទូរគមនាគមន៍ និងសេវាកម្មព័ត៌មានជាដើម។

**១៨.** មាត្រា៩ កថាខណ្ឌ២ ចែងអំពីវិធានការដែលរដ្ឋភាគីត្រូវចាត់ឡើងដើម្បីតាក់តែងប្រកាសឲ្យប្រើ និងតាមដានការអនុវត្តបទដ្ឋានជាតិអប្បបរមា សម្រាប់ការបង្កលក្ខណៈងាយស្រួលនៃសម្ភារៈបរិក្ខារ និងសេវាកម្មទាំងឡាយដែលបើកចំហ ឬផ្តល់ដល់សាធារណជន។ បទដ្ឋានទាំងនេះ ត្រូវស្របជាមួយនឹងបទដ្ឋានរបស់រដ្ឋភាគីដទៃទៀត ដើម្បីធានាឲ្យបទដ្ឋានទាំងនេះអាចអនុវត្តទៅបានរវាងគ្នាទៅវិញទៅមក ទាក់ទងនឹងការបន្លាស់ទីដោយសេរី

ក្នុងក្របខណ្ឌសេរីភាពនៃការបន្លាស់ទី និងទទួលបានសញ្ជាតិ (មាត្រា១៨) សម្រាប់ជនពិការ។ រដ្ឋភាគីក៏តម្រូវឲ្យចាត់វិធានការផងដែរ ដើម្បីធានាថា អង្គភាពឯកជន ដែលផ្តល់សម្ភារៈបរិក្ខារសម្រួល និងសេវាកម្មដែលបើកចំហ ឬផ្តល់ដល់សាធារណជន ត្រូវយកចិត្តទុកដាក់លើគ្រប់ទិដ្ឋភាព នៃការបង្កលក្ខណៈងាយស្រួលដល់ជនពិការ (មាត្រា៩ កថាខណ្ឌ២(ខ))។

**១៩.** ដោយសារតែកង្វះខាត ការបង្កលក្ខណៈងាយស្រួលច្រើនតែកើតមកពីការយល់ដឹង និងជំនាញបច្ចេកទេសមិនគ្រប់គ្រាន់នោះ មាត្រា៩ តម្រូវឲ្យរដ្ឋភាគី ត្រូវផ្តល់ការបណ្តុះបណ្តាលដល់ភាគីពាក់ព័ន្ធទាំងអស់អំពីការបង្កលក្ខណៈងាយស្រួលដល់ជនពិការ (កថាខណ្ឌ២(គ))។ មាត្រា៩នេះ មិនមានចេតនានឹងរៀបរាប់ពីដៃគូពាក់ព័ន្ធនោះទេ៖ បញ្ជីពេញលេញណាក៏ដោយ គួររួមមានអាជ្ញាធរដែលចេញអាជ្ញាប័ណ្ណសាងសង់ ក្រុមប្រឹក្សាការផ្សាយ និងបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង សភាវិស្វករ អ្នករចនាប្លង់ស្ថាបត្យករ អ្នកធ្វើផែនការទីក្រុង អាជ្ញាធរដឹកជញ្ជូន អ្នកផ្តល់សេវាកម្ម សមាជិកសហគមន៍ បណ្ឌិតសភា ព្រមទាំងជនពិការ និងអង្គការជនពិការដែរ។ ការបណ្តុះបណ្តាលទាំងនេះគួរតែផ្តល់ឲ្យមិនត្រឹមតែអ្នករចនាទំនិញ សេវាកម្ម និងផលិតផលប៉ុណ្ណោះទេ តែគួរតែផ្តល់ឲ្យអ្នកទាំងឡាយដែលផលិតរបស់ទាំងនេះផងដែរ។ ជាងនេះទៅទៀត ការពង្រឹងឲ្យមានជនពិការ ចូលរួមដោយផ្ទាល់ ក្នុង

ការអភិវឌ្ឍន៍ ផលិតផល នឹងអាចកែលម្អការយល់ដឹងអំពីតម្រូវការ ដែលមានស្រាប់ និងកែលម្អប្រសិទ្ធភាពនៃការសាកល្បង ទៅលើ ការបង្កលក្ខណៈងាយស្រួលទៀតផង។ ទីបំផុត គឺអ្នកសាងសង់ នៅលើទីតាំងសំណង់ទាំងនោះទេ ដែលជាអ្នកធ្វើឲ្យអាគារអាច បង្កលក្ខណៈងាយស្រួល ឬមិនបង្កលក្ខណៈងាយស្រួលនោះ។ វា ជាការសំខាន់ ដែលត្រូវដាក់ឲ្យដំណើរការនូវការបណ្តុះបណ្តាល និងប្រព័ន្ធតាមដានត្រួតពិនិត្យទៅលើក្រុមទាំងអស់នេះ ដើម្បីធានា ឲ្យបាននូវការអនុវត្តជាក់ស្តែង ទៅលើបទដ្ឋាននៃការបង្កលក្ខណៈ ងាយស្រួល។

២០. ការបម្លាស់ទី និងការតម្រង់ទិសនៅតាមបណ្តាអាគារ និងកន្លែងផ្សេងៗ ដែលបើកចំហដល់សាធារណជន អាចជាបញ្ហា ប្រឈមដល់ជនពិការមួយចំនួន ប្រសិនបើគ្មានស្លាកសញ្ញាគ្រប់ គ្រាន់ ព័ត៌មាននិងទំនាក់ទំនង ឬសេវាគាំទ្រនានា ដែលអាចប្រើ ប្រាស់បាន។ ដូច្នេះហើយទើបមាត្រា៩ កថាខណ្ឌ២(ឃ) និង(ង) ចែង ថា គួរត្រូវដាក់ស្លាកសញ្ញាជាអក្សរស្ទាបក្តី ជាទម្រង់ងាយអានក្តី និងងាយយល់ក្តី នៅតាមបណ្តាអាគារ និងកន្លែងផ្សេងៗដែលបើក ចំហដល់សាធារណៈជន និងចែងថា គួរត្រូវផ្តល់ទម្រង់នៃជំនួយ ផ្ទាល់ និងអន្តរការី ដោយរាប់ទាំងអ្នកនាំផ្លូវ អ្នកអាន និងអ្នកបក ប្រែភាសាសញ្ញាអាជីពផង ដើម្បីសម្រួលដល់ការបង្កលក្ខណៈ ងាយស្រួល។ ដោយគ្មានស្លាកសញ្ញា គ្មានព័ត៌មាននិងទំនាក់ទំនង

ដែលអាចប្រើបាន និងគ្មានសេវាគាំទ្រទេនោះ ការបម្លាស់ទី និង ការតម្រង់ទិសក្នុងអាគារ និងតាមអាគារនោះ ប្រហែលជាមិនអាច ទៅរួចទេសម្រាប់ជនពិការជាច្រើន ជាពិសេសអ្នកដែលទទួលរង បញ្ហាផ្នែកបញ្ញាស្មារតី។

**២១.** បើមិនបានទទួលព័ត៌មាន និងទំនាក់ទំនងទេ ការ ទទួលបានសេរីភាពនៃគំនិត និងការបញ្ចេញមតិ ព្រមទាំងសិទ្ធិ និង សេរីភាពជាមូលដ្ឋានដទៃជាច្រើនទៀតសម្រាប់ជនពិការ អាចត្រូវ បានខូចខាត និងត្រូវបានរិតត្បឹតយ៉ាងធ្ងន់ធ្ងរ។ ហេតុដូច្នេះហើយ ទើបមាត្រា៩ កថាខណ្ឌ២(ច) និង(ឆ) នៃអនុសញ្ញាចែងថារដ្ឋភាគីគួរ លើកស្ទួយទម្រង់នៃជំនួយផ្ទាល់ និងអន្តរការី ដោយរាប់ទាំងអ្នកនាំ ផ្លូវ អ្នកអាន និងអ្នកបកប្រែភាសាសញ្ញាអាជីពផង(ផ្នែក(ង)) លើក ស្ទួយទម្រង់ជំនួយ និងគាំពារសមស្របដទៃទៀតដល់ជនពិការ ដើម្បីធានាថា ពួកគេទទួលបានព័ត៌មាន និងលើកស្ទួយជនពិការ ឲ្យទទួលបានប្រព័ន្ធ និងបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងថ្មីៗ រួម ទាំងអ៊ីនធើណែត តាមរយៈការអនុវត្តជាកាតព្វកិច្ចនូវបទដ្ឋាននៃ ការបង្កលក្ខណៈងាយស្រួល។ ព័ត៌មាននិងទំនាក់ទំនងទាំងនេះ គួរអាចរកបានក្នុងទម្រង់ស្រួលអាន លក្ខណៈ និងវិធីសាស្ត្រ ដែល អាចជំនួសបាន និងដែលអាចបង្កើនលទ្ធភាពដល់ជនពិការដែល ប្រើប្រាស់ទម្រង់ លក្ខណៈ និងវិធីសាស្ត្របែបនេះ។

២២. បច្ចេកវិទ្យាថ្មីៗ អាចត្រូវបានប្រើប្រាស់ ដើម្បីលើកស្ទួយការចូលរួមឲ្យបានពេញលេញ និងដោយស្មើភាពរបស់ជនពិការនៅក្នុងសង្គម ប៉ុន្តែបានតែក្នុងករណីដែលបច្ចេកវិទ្យានេះត្រូវបានរចនានិងផលិតមកតាមវិធីមួយដែលធានាពីការអាចប្រើប្រាស់បានដោយជនពិការ។ ការវិនិយោគ និងការផលិត ការស្រាវជ្រាវថ្មីគួររួមចំណែកដល់ការលុបបំបាត់វិសមភាព មិនមែនដល់ការបង្កើតឧបសគ្គថ្មីៗនោះទេ។ ដូច្នេះហើយទើបមាត្រា៩ កថាខណ្ឌ២(ជ) អំពាវនាវឲ្យរដ្ឋភាគីលើកស្ទួយការរចនាប្លង់ ការអភិវឌ្ឍន៍ ការផលិត និងការចែកចាយនៃប្រព័ន្ធ និងបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងនៅដំណាក់កាលដំបូង ដើម្បីធ្វើឲ្យប្រព័ន្ធនិងបច្ចេកវិទ្យាទាំងនេះក្លាយជាទម្រង់មួយដែលអាចប្រើប្រាស់បានដោយជនពិការក្នុងតំលៃថោកជាអប្បបរមា។ ការប្រើប្រាស់ប្រព័ន្ធជំនួយសម្រាប់ស្តាប់ដោយរាប់បញ្ចូលទាំងប្រព័ន្ធជំនួយស្រោបពីលើត្រចៀក ដើម្បីជួយដល់ការស្តាប់ និងដល់អ្នកប្រើខ្សែជំនួយ ព្រមទាំងការបំពាក់ជណ្តើរយោងទុកជាមុនសម្រាប់អ្នកដំណើរ ដើម្បីជួយដល់ជនពិការ ក្នុងការជម្លៀសចេញពីអាគារក្នុងគ្រាមានអាសន្ន គឺជាឧទាហរណ៍មួយចំនួនអំពីវឌ្ឍនភាពផ្នែកបច្ចេកវិទ្យា ក្នុងការផ្តល់សេវាដែលមានការបង្កលក្ខណៈងាយស្រួល។

២៣. ដោយសារតែការបង្កលក្ខណៈងាយស្រួល ជាបុរេលក្ខខណ្ឌសម្រាប់ជនពិការដើម្បីឲ្យអាចរស់បានដោយឯករាជ្យដូចមានចែងក្នុងមាត្រា១៩ នៃអនុសញ្ញា និងដើម្បីឲ្យអាចចូលរួមបានពេញលេញ និងដោយស្មើភាពគ្នាក្នុងសង្គមនោះ ការបដិសេធមិនឲ្យទទួលបានការប្រើប្រាស់បរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូន រួមទាំងបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង បរិក្ខារសម្រួល និងសេវាកម្មទាំងឡាយដែលបើកចំហ និងផ្តល់ដល់សាធារណជននោះ ត្រូវចាត់ទុកថាស្ថិតក្នុងបរិបទនៃការរើសអើង។ "ការចាត់វាល់វិធានការសមស្រប រួមទាំងវិធានការច្បាប់ ដើម្បីកែប្រែ ឬលុបចោលច្បាប់ បទបញ្ញា ទំនៀមទម្លាប់ និងការអនុវត្តជាក់ស្តែងដែលមានស្រាប់ដែលបង្កើតជាការរើសអើងប្រឆាំងនឹងជនពិការ (មាត្រា៤ កថាខណ្ឌ១(ខ)) បង្កើតបានជាកាតព្វកិច្ចទូទៅចម្បងៗ សម្រាប់គ្រប់រដ្ឋភាគី។ "រដ្ឋភាគីត្រូវហាមឃាត់រាល់ការរើសអើងដោយសារតែពិការភាព និងធានាដល់ជនពិការនូវការការពារតាមផ្លូវច្បាប់ដោយស្មើភាពគ្នានិងដោយមានប្រសិទ្ធភាពប្រឆាំងនឹងការរើសអើងតាមគ្រប់រូបភាព" (មាត្រា៥ កថាខណ្ឌ២)។ "ដើម្បីលើកស្ទួយសមភាព និងលុបបំបាត់ការរើសអើង រដ្ឋភាគីត្រូវចាត់វាល់វិធានការសមស្រប ដើម្បីធានាពីការផ្តល់ដំណោះស្រាយសមហេតុផល" (មាត្រា៥ កថាខណ្ឌ៣)។

២៤. គួរមានការបែងចែកឲ្យបានច្បាស់ រវាងកាតព្វកិច្ចធានាពីការទទួលបានរបស់របរ ហេដ្ឋារចនាសម្ព័ន្ធ ទំនិញ ផលិតផល និងសេវាកម្មដែលផលិត សាងសង់ ឬរចនាថ្មីៗ និងកាតព្វកិច្ចលុបបំបាត់ឧបសគ្គរារាំង និងធានាពីការទទួលបានការប្រើប្រាស់បរិស្ថានរូបវន្តមានស្រាប់ និងមធ្យោបាយដឹកជញ្ជូន ព័ត៌មាន និងទំនាក់ទំនង ព្រមទាំងសេវាកម្មដែលមានស្រាប់ បើកចំហដល់សាធារណជនទូទៅ។ កាតព្វកិច្ចទូទៅមួយផ្សេងទៀតរបស់រដ្ឋភាគី គឺ "ព្យាយាម ឬលើកស្ទួយការស្រាវជ្រាវ និងអភិវឌ្ឍន៍ទំនិញ សេវាកម្ម សម្ភារៈ និងគ្រឿងបរិក្ខារដែលរចនាជាសកល ដូចមានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ ដែលគួរតម្រូវឲ្យមានការសម្របតាមជាអប្បបរមាតាមតែអាចធ្វើទៅបាន និងមានតម្លៃថោកដើម្បីបំពេញតម្រូវការជាក់ស្តែងរបស់ជនពិការ លើកស្ទួយការប្រើប្រាស់ និងភាពអាចរកបាននូវរបស់ទាំងអស់ខាងលើនេះ និងដើម្បីលើកស្ទួយការរចនាប្លង់ជាសកល ក្នុងការអភិវឌ្ឍន៍បទដ្ឋាន និងគោលការណ៍ណែនាំ" (មាត្រា៤ កថាខណ្ឌ៤(ច))។ របស់របរ ហេដ្ឋារចនាសម្ព័ន្ធ គ្រឿងបរិក្ខារ ទំនិញ ផលិតផល និងសេវាកម្មថ្មីៗទាំងអស់ ត្រូវតែរចនាឡើងតាមវិធីមួយ ដែលធ្វើឲ្យរបស់របរទាំងអស់ខាងលើនេះអាចប្រើប្រាស់បានពេញលេញដោយជនពិការ ស្របតាមគោលការណ៍ណែនាំស្តីពីការរចនាប្លង់ជាសកល។ រដ្ឋភាគីមានកាតព្វកិច្ចក្នុងការធានាថា ជនពិការអាចទទួលបានការប្រើប្រាស់បរិស្ថានរូប

វន្តដែលមានស្រាប់ និងមធ្យោបាយដឹកជញ្ជូន ព័ត៌មាននិងទំនាក់ទំនង ព្រមទាំងសេវាកម្មដែលមានស្រាប់ដែលបើកចំហដល់សាធារណជនទូទៅ។ ប៉ុន្តែ ដោយសារតែកាតព្វកិច្ចនេះត្រូវអនុវត្តជាបន្តបន្ទាប់នោះ រដ្ឋភាគីគួរកំណត់ក្របខ័ណ្ឌពេលវេលាឲ្យបានជាក់លាក់ និងលៃលកធនធានឲ្យបានគ្រប់គ្រាន់ ក្នុងការលុបបំបាត់ឧបសគ្គដែលមានស្រាប់។ បន្ថែមពីលើនេះទៀត រដ្ឋភាគីគួរតែដាក់បញ្ញត្តិឲ្យបានច្បាស់លាស់ អំពីភារកិច្ចរបស់អាជ្ញាធរផ្សេងៗ (រួមទាំងអាជ្ញាធរថ្នាក់តំបន់ និងថ្នាក់មូលដ្ឋាន) ព្រមទាំងអង្គភាពនានា (រួមទាំងអង្គភាពឯកជនផង) ដែលត្រូវអនុវត្ត ដើម្បីធានាឲ្យបានការបង្កលក្ខណៈងាយស្រួល។ រដ្ឋភាគីក៏គួរដាក់បញ្ញត្តិផងដែរ ឲ្យមានយន្តការឃ្លាំមើលដ៏មានប្រសិទ្ធភាព ដែលត្រូវធានាឲ្យមានការបង្កលក្ខណៈងាយស្រួល និងបញ្ញត្តិពីទណ្ឌកម្មប្រឆាំងអ្នកទាំងឡាយណាដែលខកខានមិនបានអនុវត្តស្តង់ដារនៃការបង្កលក្ខណៈងាយស្រួល។

**២៥.** ការបង្កលក្ខណៈងាយស្រួលពាក់ព័ន្ធដល់ក្រុមផ្សេងៗ រីឯដំណោះស្រាយសមហេតុផលពាក់ព័ន្ធនឹងបុគ្គល។ នេះមានន័យថា ភារកិច្ចផ្តល់ការបង្កលក្ខណៈងាយស្រួល គឺជាភារកិច្ច*ត្រូវផ្តល់មុនមានបាតុភាពកើតឡើង*។ ដូច្នេះ រដ្ឋភាគីមានភារកិច្ចផ្តល់ការបង្កលក្ខណៈងាយស្រួល មុនពេលទទួលបានសំណូមពរពីបុគ្គល ដើម្បីចេញ-ចូល ឬប្រើប្រាស់កន្លែង ឬសេវាកម្មណាមួយ

នោះ។ រដ្ឋភាគីត្រូវកំណត់បទដ្ឋាននៃការបង្កលក្ខណៈងាយស្រួល ដែលត្រូវតែអនុម័ត ដោយមានការពិគ្រោះយោបល់ជាមួយអង្គការជនពិការ ហើយរដ្ឋត្រូវតែបញ្ជាក់ឲ្យច្បាស់ដល់អ្នកផ្តល់សេវាកម្ម អ្នកសាងសង់ និងភាគីពាក់ព័ន្ធដទៃទៀត។ បទដ្ឋាននៃការបង្កលក្ខណៈងាយស្រួលនេះ ត្រូវតែមានភាពទូលាយ និងធ្វើជាស្តង់ដារតែមួយ។ ក្នុងករណីដែលបុគ្គលមានភាពអន់ខ្សោយដោយកម្រ ដែលមិនត្រូវបានគិតគូរដល់ នៅពេលរៀបចំបង្កើតបទដ្ឋាននៃការបង្កលក្ខណៈងាយស្រួល ឬមិនប្រើប្រាស់ទម្រង់ វិធីសាស្ត្រ ឬមធ្យោបាយដែលផ្តល់ឲ្យ ដើម្បីសម្រេចបានការបង្កលក្ខណៈងាយស្រួល (ឧទាហរណ៍ មិនអាចអានអក្សរស្ទាបបាន) សូម្បីតែការអនុវត្តតាមបទដ្ឋាននៃការបង្កលក្ខណៈងាយស្រួល ក៏មិនអាចគ្រប់គ្រាន់ ដើម្បីធានាឲ្យពួកគេអាចទទួលបានការប្រើប្រាស់នេះទៀតផង។ ក្នុងករណីបែបនេះ ដំណោះស្រាយសមហេតុផលត្រូវយកមកអនុវត្ត។ យោងតាមអនុសញ្ញានេះ រដ្ឋភាគីមិនត្រូវបានអនុញ្ញាតិឲ្យប្រើវិធានការកាត់បន្ថយចំណាយថាជាលេសមួយដើម្បីគេចចេញពីការធានាឲ្យមានការបង្កលក្ខណៈងាយស្រួលជាបន្តបន្ទាប់ ដល់ជនពិការនោះទេ។ កាតព្វកិច្ចអនុវត្តការបង្កលក្ខណៈងាយស្រួល គឺជាកាតព្វកិច្ច *ដែលគ្មានលក្ខខណ្ឌ* តួយ៉ាង អង្គភាពដែលជាប់កាតព្វកិច្ចមិនអាចយកលេសពីភាពអកម្មថាជាបន្ទុកនៃការផ្តល់ឲ្យទទួលបានការប្រើប្រាស់ដល់ជនពិការនោះទេ។ ផ្ទុយទៅវិញ ភារកិច្ចនៃការផ្តល់ដំណោះស្រាយសមហេតុផល មានអត្ថិភាពបាន តែក្នុងករណី

ដែលការអនុវត្តដំណោះស្រាយនោះ មិនបង្កជាបន្ទុកធ្ងន់ធ្ងរទៅលើភាគីអង្គភាពនោះតែប៉ុណ្ណោះ។

**២៦.** ភារកិច្ចផ្តល់ដំណោះស្រាយសមហេតុផល គឺជាភារកិច្ច *ចាប់ពីពេលនេះទៅ* ដែលមានន័យថា វាអាចអនុវត្តបានចាប់ពីគ្រាដែលជនពិការអ្វីមួយម្នាក់ ត្រូវការគ្រឿងជំនួយនេះ នៅក្នុងស្ថានភាពណាមួយ (ដូចជានៅកន្លែងធ្វើការ នៅសាលារៀនជាដើម) ដើម្បីទទួលបានសិទ្ធិរបស់ខ្លួន ដោយឈរលើមូលដ្ឋានស្មើភាពគ្នាក្នុងបរិបទជាក់លាក់ណាមួយ។ ក្នុងស្ថានភាពនេះ បទដ្ឋាននៃការបង្កលក្ខណៈងាយស្រួលអាចជាសូចនាករមួយ ប៉ុន្តែមិនអាចត្រូវយកធ្វើជាអាជ្ញាបញ្ញាទេ។ ដំណោះស្រាយសមហេតុផល អាចត្រូវយកមកប្រើជាមធ្យោបាយមួយ ក្នុងការធានាឲ្យមានការបង្កលក្ខណៈងាយស្រួលដល់បុគ្គលពិការនោះ ក្នុងស្ថានភាពជាក់លាក់ណាមួយនោះ។ ដំណោះស្រាយសមហេតុផល ស្វះស្វែងសម្រេចបាននូវយុត្តិធម៌បុគ្គល ក្នុងន័យដែលជួយធានាឲ្យមានសមភាព និងមិនមានការរើសអើង ដោយយកចិត្តទុកដាក់ដល់សេចក្តីថ្លៃថ្នូរស្វ័យភាព និងជម្រើសនានារបស់បុគ្គលនោះ។ ដូច្នេះ បុគ្គលណាម្នាក់ដែលមានភាពអន់ខ្សោយដោយកម្រ អាចស្នើសុំឲ្យមានដំណោះស្រាយ ដែលមិនស្ថិតនៅក្នុងវិសាលភាពនៃបទដ្ឋានស្តង់ដារនៃការបង្កលក្ខណៈងាយស្រួលបាន។

## III. កាតព្វកិច្ចរបស់រដ្ឋភាគី

២៧. ទោះបីជាមានការធានា ក្នុងការទទួលបានការប្រើប្រាស់បរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូន ព័ត៌មាននិងទំនាក់ទំនង ព្រមទាំងសេវាកម្មដែលបើកចំហដល់សាធារណជនទូទៅជារឿយៗ គឺជាបុរេលក្ខខណ្ឌសម្រាប់ការទទួលបានប្រកបដោយសុវត្ថិភាពនូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយផ្សេងៗ សម្រាប់ជនពិការក៏ដោយ ក៏រដ្ឋភាគីអាចធានាថា ការទទួលបានការប្រើប្រាស់ទាំងនេះ ត្រូវសម្រេចបានតាមការអនុវត្តជាបន្តបន្ទាប់ នៅពេលណាចាំបាច់ ក៏ដូចជាតាមការប្រើប្រាស់កិច្ចសហប្រតិបត្តិការអន្តរជាតិ។ ការវិភាគស្ថានភាពដើម្បីកំណត់ពីឧបសគ្គ ឬរបាំងផ្សេងៗដែលត្រូវដកចេញនោះ អាចអនុវត្តបានក្នុងលក្ខណៈមួយប្រកបដោយប្រសិទ្ធភាព និងក្នុងក្របខណ្ឌពីរយៈពេលខ្លី ទៅរយៈពេលមធ្យម។ របាំងនានាគួរត្រូវបានដកចេញ តាមវិធីមួយដែលត្រូវធ្វើជាបន្តបន្ទាប់ និងមានលក្ខណៈជាប្រព័ន្ធ ឲ្យបានជាលំដាប់ និងត្រូវធ្វើជាប្រចាំ។

២៨. រដ្ឋភាគីមានកាតព្វកិច្ចអនុម័ត ប្រកាសឲ្យប្រើ និងតាមឃ្លាំមើលបទដ្ឋាននៃការបង្កលក្ខណៈងាយស្រួលថ្នាក់ជាតិ។ ប្រសិនបើមិនទាន់មានច្បាប់ពាក់ព័ន្ធនៅឡើយ ការអនុម័តក្របខណ្ឌច្បាប់សមរម្យមួយ គឺជាជំហានដំបូងដែលត្រូវធ្វើ។ រដ្ឋភាគីគួរធ្វើការត្រួតពិនិត្យឡើងវិញ ឲ្យបានទូលំទូលាយទៅលើច្បាប់នានា ពាក់ព័ន្ធនឹង

ការបង្កលក្ខណៈងាយស្រួល ដើម្បីកំណត់អត្តសញ្ញាណ តាមឃ្លាំមើល និងដោះស្រាយពីចន្លោះខ្វះខាតនៅក្នុងច្បាប់ និងក្នុងការអនុវត្ត។ ជារឿយៗ ច្បាប់ពិការភាពមិនបានបញ្ចូលបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង ទៅក្នុងនិយមន័យនៃការបង្កលក្ខណៈងាយស្រួលទេ ខណៈដែលច្បាប់ស្តីពីសិទ្ធិពិការភាពពាក់ព័ន្ធជាមួយនឹងការទទួលបានការប្រើប្រាស់ដោយមិនរើសអើង ក្នុងវិស័យមួយចំនួន ដូចជា លទ្ធកម្ម ការងារ និងការអប់រំ មិនបានបញ្ចូលការទទួលបានបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង ព្រមទាំងទំនិញ និងសេវាកម្មជាច្រើន ដែលជាស្នូលនៃសង្គមទំនើប ដែលត្រូវផ្តល់ជូនតាមបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង។ បញ្ហាសំខាន់គឺថាការត្រួតពិនិត្យឡើងវិញ និងការអនុម័តច្បាប់ និងបទប្បញ្ញត្តិទាំងនេះត្រូវតែប្រព្រឹត្តទៅ ដោយមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយជនពិការ និងអង្គការតំណាងជនពិការ(មាត្រា៤ កថាខណ្ឌ៣) ព្រមទាំងជាមួយភាគីពាក់ព័ន្ធដទៃទាំងអស់ រួមទាំងសមាជិកនៃសហគមន៍បណ្ឌិតសភា សមាគមស្ថាបត្យករជំនាញ អ្នកធ្វើផែនការទីក្រុង វិស្វករ និងអ្នករចនា។ ច្បាប់គួរមានបញ្ចូល និងត្រូវផ្អែកលើគោលការណ៍នៃការរចនាប្លង់ជាសកល ដូចដែលតម្រូវឲ្យមានក្នុងអនុសញ្ញានេះ (មាត្រា៤ កថាខណ្ឌ១(ច))។ ច្បាប់គួរតែចែងពីការអនុវត្តជាកាតព្វកិច្ច ចំពោះបទដ្ឋាននៃការបង្កលក្ខណៈងាយស្រួលពីការដាក់ទណ្ឌកម្ម រួមទាំងការពិន័យផងដល់អ្នកទាំងឡាយណាដែលមិនអនុវត្តតាម។

២៩. វាជាការមានប្រយោជន៍ ដើម្បីបញ្ជាបបទដ្ឋាននៃការបង្កលក្ខណៈងាយស្រួល ដែលដាក់បញ្ញត្តិទៅលើវិស័យផ្សេងៗ ដែលត្រូវតែអាចប្រើប្រាស់បាន-បរិស្ថានរូបវន្តនៅក្នុងច្បាប់ស្តីពីការសាងសង់ និងការធ្វើផែនការ មធ្យោបាយដឹកជញ្ជូនក្នុងច្បាប់ស្តីពីការដឹកជញ្ជូនសាធារណៈ តាមផ្លូវអាកាស ផ្លូវដែក ផ្លូវថ្នល់ និងផ្លូវទឹក ព្រមទាំងព័ត៌មាននិងទំនាក់ទំនង និងសេវាកម្មនានាដែលបើកចំហដល់សាធារណជនទូទៅ។ ទោះជាយ៉ាងណាក៏ដោយ ការបង្កលក្ខណៈងាយស្រួល គប្បីដាក់បញ្ចូលក្នុងច្បាប់ទូទៅ និងច្បាប់ជាក់លាក់មួយចំនួនស្តីពីឱកាសស្មើភាពគ្នា សមភាព និងការចូលរួម ក្នុងបរិបទនៃការហាមឃាត់មិនឲ្យមានការរើសអើងដោយសារពិការភាព។ ការបដិសេធមិនឲ្យទទួលបានការប្រើប្រាស់ គួរតែមានចែងឲ្យបានច្បាស់ថាជាទង្វើរើសអើងដែលត្រូវតែហាមឃាត់។ ជនពិការ ដែលត្រូវបានបដិសេធមិនឲ្យទទួលបានការប្រើប្រាស់បរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូន ព័ត៌មាននិងទំនាក់ទំនង ឬសេវាកម្មនានាដែលបើកចំហរដល់សាធារណជន គួរមានដំណោះស្រាយតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាព ដែលគេអាចប្រើប្រាស់បាន។ នៅពេលកំណត់និយមន័យអំពីបទដ្ឋាននៃការបង្កលក្ខណៈងាយស្រួល រដ្ឋភាគីត្រូវពិចារណាអំពីភាពផ្សេងៗគ្នានៃជនពិការ ហើយត្រូវធានាថា ការបង្កលក្ខណៈងាយស្រួលត្រូវផ្តល់ដល់មនុស្សគ្រប់ភេទ គ្រប់វ័យ និងគ្រប់ប្រភេទពិការភាព។ ចំណែក

មួយនៃការងារបញ្ចូលភាពផ្សេងៗគ្នានៃជនពិការ ទៅក្នុងបទប្បញ្ញត្តិនៃការបង្កលក្ខណៈងាយស្រួល គឺជាការទទួលស្គាល់ថា ជនពិការមួយចំនួនត្រូវការជំនួយរបស់មនុស្ស ឬជំនួយរបស់សត្វ ដើម្បីទទួលបានការបង្កលក្ខណៈងាយស្រួលពេញលេញ (ដូចជា ជំនួយផ្ទាល់ខ្លួន ការបកប្រែភាសាសញ្ញា ការបកប្រែភាសាសញ្ញាតាមកាយវិញ្ញាណ ឬសត្វឆ្កែសម្រាប់នាំផ្លូវជាដើម)។ ឧទាហរណ៍ វាត្រូវតែមានចែងថា ការហាមមិនឲ្យយកសត្វឆ្កែសម្រាប់នាំផ្លូវចូលទៅក្នុងអាគារ ឬទីសាធារណៈណាមួយ គឺជាទង្វើរើសអើងដោយសារមូលហេតុពិការភាពដែលត្រូវហាមឃាត់។

៣០. វាជាការចាំបាច់បង្កើតបទដ្ឋានអប្បបរមាសំរាប់ការបង្កលក្ខណៈងាយស្រួលនៃសេវាកម្មផ្សេងៗដែលផ្តល់ដោយសហគ្រាសសាធារណៈ និងឯកជន ដល់បុគ្គលមានភាពអន់ខ្សោយប្រភេទផ្សេងៗគ្នា។ ឧបករណ៍បង្អែក មានដូចជា អនុសាសន៍ជាបញ្ជីតាមដានការបង្កលក្ខណៈងាយស្រួលផ្នែកទូរគមនាគមន៍ITU-T សម្រាប់សកម្មភាពធ្វើបទដ្ឋានីយកម្ម(២០០៦) និង "គោលការណ៍ណែនាំនៃការបង្កលក្ខណៈងាយស្រួលផ្នែកទូរគមនាគមន៍ដល់មនុស្សចាស់ និងជនពិការ" (អនុសាសន៍F.790 នៃ ITU-T) គួរត្រូវបានបញ្ជ្រាបនៅពេលណាដែលបទដ្ឋានថ្មីទាក់ទងនឹងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងត្រូវបានរៀបចំបង្កើតឡើង។ ការធ្វើបែបនេះ នឹងធ្វើឲ្យមានទូទៅនីយកម្ម នៃការរចនាប្លង់សកល ក្នុងការរៀបចំបង្កើតបទ

ដ្ឋាន។ រដ្ឋភាគីត្រូវបង្កើតក្របខណ្ឌច្បាប់មួយ ដែលមានគោលកំណត់ជាក់លាក់ អាចអនុវត្តបាន និងមានពេលវេលាកំណត់ច្បាស់លាស់សំរាប់ការតាមឃ្លាំមើល និងការវាយតម្លៃអំពីការកែតម្រូវ និងការកែសម្រួលជាបន្តបន្ទាប់ ដោយអង្គភាពឯកជននានា ដែលមានសេវាមិនបង្កលក្ខណៈងាយស្រួលពីមុន ឲ្យទៅជាសេវាដែលមានការបង្កលក្ខណៈងាយស្រួលវិញ។ រដ្ឋភាគីត្រូវធានាផងដែរថាគ្រប់ទំនិញ និងសេវាកម្មដែលត្រូវទិញថ្មីៗ ត្រូវតែអាចប្រើប្រាស់បានយ៉ាងពេញលេញដោយជនពិការ។ បទដ្ឋានអប្បបរមា ត្រូវតែរៀបចំឡើង ដោយមានការពិគ្រោះយោបល់យ៉ាងជិតដិតជាមួយជនពិការ និងអង្គការតំណាងជនពិការ ដោយអនុលោមតាមមាត្រា ៤ កថាខណ្ឌ៣ នៃអនុសញ្ញានេះ។ បទដ្ឋាននេះ ក៏អាចត្រូវរៀបចំបង្កើតឡើងផងដែរ ក្រោមកិច្ចសហការជាមួយរដ្ឋភាគីដទៃទៀត ព្រមទាំងអង្គការ និងទីភ្នាក់ងារអន្តរជាតិផ្សេងទៀត តាមរយៈកិច្ចសហប្រតិបត្តិការអន្តរជាតិស្របតាមមាត្រា៣២ នៃអនុសញ្ញានេះ។ រដ្ឋភាគីត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងក្រុមសិក្សា ITU ក្នុងផ្នែកវិទ្យុ បទដ្ឋានីយកម្ម និងការអភិវឌ្ឍន៍តាមវិស័យនានារបស់សហជីព ដែលធ្វើការយ៉ាងសកម្មក្នុងការបញ្ជ្រាបការបង្កលក្ខណៈងាយស្រួលនេះ ក្នុងការរៀបចំបង្កើតបទដ្ឋានទូរគមនាគមន៍អន្តរជាតិ / បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង ព្រមទាំងការលើកកម្ពស់ការយល់ដឹងរបស់វិស័យឧស្សាហកម្ម និងរដ្ឋាភិបាល ស្តីពីតម្រូវការ

បង្កើនការទទួលបានបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង សម្រាប់ជនពិការ។ កិច្ចសហប្រតិបត្តិការបែបនេះអាចមានប្រយោជន៍ដល់ការបង្កើត និងការលើកស្ទួយបទដ្ឋានអន្តរជាតិ ដែលរួមចំណែកដល់អន្តរប្រតិបត្តិការទៅលើទំនិញ និងសេវាកម្ម។ ក្នុងវិស័យសេវាកម្មពាក់ព័ន្ធនឹងទំនាក់ទំនង រដ្ឋភាគីត្រូវធានាឲ្យបានយ៉ាងហោចណាស់នូវគុណភាពសេវាកម្មជាអប្បបរមា ជាពិសេស សម្រាប់ប្រភេទសេវាកម្មថ្មីៗ ដូចជាជំនួយផ្ទាល់ខ្លួន និងការបកប្រែភាសាសញ្ញា ប្រព័ន្ធសញ្ញាតាមកាយវិញ្ញាណ ដែលមានគោលបំណងសម្រេចឲ្យបានតាមបទដ្ឋានីយកម្ម។

**៣១.** ជាចំណែកមួយនៃការពិនិត្យឡើងវិញទៅលើច្បាប់ស្ដីពីការបង្កលក្ខណៈងាយស្រួលនេះ រដ្ឋភាគីត្រូវពិចារណា ហើយបើចាំបាច់ ត្រូវធ្វើវិសោធនកម្មទៅលើច្បាប់ទាំងឡាយដែលហាមឃាត់មិនឲ្យមានការរើសអើងដោយមូលហេតុពិការភាព។ ក្នុងកម្រិតអប្បបរមា ស្ថានភាពខាងក្រោមនេះដែលខ្វះការបង្កលក្ខណៈងាយស្រួល បានរារាំងជនពិការមិនឲ្យទទួលបានការប្រើប្រាស់សេវាកម្មឬគ្រឿងសម្រួលដែលបើកចំហដល់សាធារណជនទូទៅ គួរត្រូវចាត់ទុកថាជាទង្វើរើសអើងដោយសារពិការភាពត្រូវបានហាមឃាត់៖

i. នៅទីដែលសេវាកម្មឬគ្រឿងសម្រួលត្រូវបានបង្កើតឡើងបន្ទាប់ពីមានការណែនាំឲ្យប្រើបទដ្ឋាននៃការបង្កលក្ខណៈងាយស្រួល

ii នៅកន្លែងណា ដែលគេអាចផ្តល់ការទទួលបានការប្រើប្រាស់គ្រឿងសម្រួល ឬសេវាកម្ម (នៅពេលណាដែលគ្រឿងសម្រួល ឬសេវាកម្មទាំងនេះមាន) តាមរយៈដំណោះស្រាយសមហេតុផល

៣២. ជាផ្នែកមួយនៃការពិនិត្យឡើងវិញទៅលើ ច្បាប់ស្តីពីការបង្កលក្ខណៈងាយស្រួល រដ្ឋភាគីក៏ត្រូវពិចារណាផងដែរទៅលើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។ រដ្ឋភាគីត្រូវធានាថា នីតិវិធីលទ្ធកម្មសាធារណៈ មានបញ្ចូលលក្ខខណ្ឌតម្រូវនៃការបង្កលក្ខណៈងាយស្រួល។ វាជាការមិនអាចទទួលយកបានទេ ក្នុងការយកមូលនិធិសាធារណៈមកប្រើប្រាស់ ដើម្បីបង្កើត ឬធ្វើឲ្យមានជានិរន្តនូវវិសមភាពដែលកើតចេញមកដោយជៀសមិនរួចពីសេវាកម្ម និងគ្រឿងសម្រួលដែលមិនអាចប្រើប្រាស់បានដោយជនពិការ។ លទ្ធកម្មសាធារណៈត្រូវបានប្រើដើម្បីអនុវត្តសកម្មភាពជាវិជ្ជមាន ស្របតាមបទប្បញ្ញត្តិមាត្រា៥ កថាខណ្ឌ៤ នៃអនុសញ្ញានេះ ដើម្បីធានានូវការបង្កលក្ខណៈងាយស្រួល និងសមភាពតាមព្រឹត្តន័យសម្រាប់ជនពិការ។

៣៣. រដ្ឋភាគីគួរអនុម័តផែនការសកម្មភាព និងយុទ្ធសាស្ត្រទាំងឡាយ ដើម្បីកំណត់របាំងនានាដែលមានដល់ការបង្កលក្ខណៈងាយស្រួល គួរកំណត់ក្របខ័ណ្ឌពេលវេលា ដោយមានកាល

បរិច្ឆេទជាក់លាក់ ព្រមទាំងផ្តល់ទាំងធនធានមនុស្ស ទាំងសម្ភារៈចាំបាច់សម្រាប់លុបបំបាត់របាំងទាំងនេះ។ នៅពេលអនុម័តហើយ ផែនការសកម្មភាព និងយុទ្ធសាស្ត្រទាំងនោះ គួរត្រូវអនុវត្តឲ្យបានតឹងរឹង។ រដ្ឋភាគីក៏គួរពង្រឹងយន្តការតាមដានត្រួតពិនិត្យរបស់ខ្លួន ដើម្បីធានាឲ្យមានការបង្កលក្ខណៈងាយស្រួល ហើយរដ្ឋភាគីគួរបន្តផ្តល់មូលនិធិឲ្យបានគ្រប់គ្រាន់ ដើម្បីលុបបំបាត់របាំងទាំងនោះឲ្យទៅជាការបង្កលក្ខណៈងាយស្រួល ព្រមទាំងបណ្តុះបណ្តាលបុគ្គលិកតាមឃ្លាំមើល។ ដោយសារតែបទដ្ឋាននៃការបង្កលក្ខណៈងាយស្រួល ជារឿយៗ ត្រូវបានអនុវត្តនៅថ្នាក់មូលដ្ឋាននោះ ការកសាងសមត្ថភាពជាបន្តបន្ទាប់ ដល់អាជ្ញាធរមូលដ្ឋាន ដែលទទួលខុសត្រូវក្នុងការតាមឃ្លាំមើលការអនុវត្តបទដ្ឋានទាំងនោះ ពិតជាមានសារៈសំខាន់ខ្លាំងណាស់។ រដ្ឋភាគីមានកាតព្វកិច្ចរៀបចំបង្កើតឲ្យមានក្របខណ្ឌតាមឃ្លាំមើលប្រកបដោយប្រសិទ្ធភាពមួយ និងបង្កើតអង្គភាពតាមឃ្លាំមើលដែលមានប្រសិទ្ធភាពមួយចំនួន ដែលមានសមត្ថភាពគ្រប់គ្រាន់ និងអាណត្តិការងារសមរម្យ ដើម្បីធានាថា ផែនការយុទ្ធសាស្ត្រ និងបទដ្ឋាននីយកម្ម ត្រូវបានអនុវត្ត និងពង្រឹង។

## IV. អន្តរទំនាក់ទំនងជាមួយមាត្រាផ្សេងទៀត

៣៤. ភារកិច្ចរបស់រដ្ឋភាគី ដើម្បីធានាការទទួលបានការប្រើប្រាស់បរិស្ថានរូបវ័ន្ត មធ្យោបាយដឹកជញ្ជូន ព័ត៌មាននិងទំនាក់ទំនង ព្រមទាំងសេវាកម្មដែលបើកចំហរដល់សាធារណជនទូទៅសម្រាប់ជនពិការ គួរតែត្រូវបានឃើញតាមទស្សនៈវិស័យសមភាពនិងការមិនរើសអើង។ ការបដិសេធមិនឲ្យទទួលបានការប្រើប្រាស់បរិស្ថានរូបវ័ន្ត មធ្យោបាយដឹកជញ្ជូន ព័ត៌មាននិងទំនាក់ទំនង ព្រមទាំងសេវាកម្ម ដែលបើកចំហដល់សាធារណជនទូទៅ បង្កើតជាទង្វើរើសអើងមួយដោយសារពិការភាព ដែលជាទង្វើមួយត្រូវបានហាមឃាត់ក្នុងមាត្រា៥ នៃអនុសញ្ញា។ ការធានាឲ្យមានការបង្កលក្ខណៈងាយស្រួលសម្រាប់ពេលអនាគត គួរត្រូវយល់ឃើញក្នុងបរិបទនៃការអនុវត្តកាតព្វកិច្ចទូទៅ ដើម្បីរៀបចំបង្កើតឲ្យបាននូវទំនិញ សេវាកម្ម បរិក្ខារ និងគ្រឿងសម្រួលដែលត្រូវរចនាឡើងជាសកល (មាត្រា៤ កថាខណ្ឌ១(ច))។

៣៥. ការលើកកម្ពស់ការយល់ដឹង គឺជាបុរេលក្ខខណ្ឌមួយសម្រាប់ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការឲ្យមានប្រសិទ្ធភាព។ ដោយសារតែការបង្កលក្ខណៈងាយស្រួលនេះ ជារឿយៗ ត្រូវបានយល់ក្នុងន័យចង្អៀត ថាត្រឹមតែជាការបង្កលក្ខណៈងាយស្រួលចំពោះបរិស្ថាន ដែលត្រូវបានកសាងឡើង (ដែលជាសំខាន់នោះ

ប៉ុន្តែនោះគ្រាន់តែជាជ្រុងមួយនៃការទទួលបានការប្រើប្រាស់សម្រាប់ជនពិការប៉ុណ្ណោះ)។ រដ្ឋភាគីត្រូវខិតខំលើកកម្ពស់ការយល់ដឹងនេះជាលក្ខណៈប្រព័ន្ធនិងជាបន្តបន្ទាប់អំពីការបង្កលក្ខណៈងាយស្រួលនោះ នៅក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។ ប្រភេទគ្របដណ្តប់គ្រប់ជ្រុងជ្រោយនៃការបង្កលក្ខណៈងាយស្រួល គួរត្រូវបានលើកឡើង សម្រាប់ការផ្តល់ឲ្យមានការទទួលបានការប្រើប្រាស់បរិស្ថានរូបវ័ន្ត មធ្យោបាយដឹកជញ្ជូន ព័ត៌មាននិងទំនាក់ទំនង ព្រមទាំងសេវាកម្ម។ ការលើកកម្ពស់ការយល់ដឹងនេះ ក៏ត្រូវសង្កត់ធ្ងន់ដែរថា ភារកិច្ចតាមឃ្លាំមើលបទដ្ឋាននៃការបង្កលក្ខណៈងាយស្រួលត្រូវអនុវត្តដោយស្មើភាពគ្នាចំពោះវិស័យសាធារណៈ និងវិស័យឯកជន។ការណ៍នេះជួយលើកកម្ពស់ការអនុវត្តការរចនាប្លង់សកលហើយគំនិតដែលថាការរចនា និងការសាងសង់តាមបែបបង្កលក្ខណៈងាយស្រួល ចាប់ពីដំណាក់កាលដំបូងបំផុត គឺជាការចំណាយមានប្រសិទ្ធភាព និងសន្សំសំចៃ។ ការលើកកម្ពស់ការយល់ដឹង គួរតែអនុវត្តដោយមានកិច្ចសហការជាមួយជនពិការ អង្គការតំណាងជនពិការ និងអ្នកជំនាញបច្ចេកទេស។ គួរផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការកសាងសមត្ថភាពសម្រាប់ការអនុវត្ត និងការតាមឃ្លាំមើលពីការអនុវត្តបទដ្ឋាននៃការបង្កលក្ខណៈងាយស្រួល។ ប្រព័ន្ធផ្សព្វផ្សាយ គួរយកចិត្តទុកដាក់អំពីការបង្កលក្ខណៈងាយ

ស្រួលនេះ មិនត្រឹមតែក្នុងកម្មវិធី និងសេវាកម្មរបស់ខ្លួនសម្រាប់ជនពិការនោះទេ តែថែមទាំងត្រូវដើរតួនាទីសកម្មមួយក្នុងការលើកស្ទួយការបង្កលក្ខណៈងាយស្រួល និងរួមចំណែកដល់ការលើកកម្ពស់ការយល់ដឹងផង។

៣៦. ការធានាឲ្យទទួលបានការប្រើប្រាស់ពេញលេញទៅលើបរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូន ព័ត៌មាននិងទំនាក់ទំនងព្រមទាំងសេវាកម្មដែលបើកចំហដល់សាធារណជនទូទៅ តាមពិតទៅគឺជាបុរេលក្ខខណ្ឌដ៏សំខាន់បំផុត ចំពោះការទទួលបានដោយប្រសិទ្ធភាពនូវសិទ្ធិជាច្រើនដែលមានចែងក្នុងអនុសញ្ញានេះ។ ក្នុងស្ថានភាពដែលមានហានិភ័យ គ្រោះមហន្តរាយធម្មជាតិ និងជម្លោះប្រដាប់អាវុធ សេវាសង្គ្រោះបន្ទាន់ត្រូវតែអាចប្រើប្រាស់បានដោយជនពិការ បើមិនដូច្នោះទេ ជីវិតរបស់ជនពិការមិនអាចត្រូវបានសង្គ្រោះ ឬសុខុមាលភាពរបស់ពួកគេ មិនទទួលបានការការពារឡើយ(មាត្រា១១)។ ការបង្កលក្ខណៈងាយស្រួល ត្រូវតែដាក់បញ្ចូលជាអាទិភាពទៅក្នុងកិច្ចប្រឹងប្រែងស្តារឡើងវិញក្រោយគ្រោះមហន្តរាយ។ ដូច្នេះ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ត្រូវតែអាចប្រើប្រាស់បានដោយជនពិការ និងដាក់បញ្ចូលពិការភាពទៅក្នុងនោះ។

៣៧. សិទ្ធិទទួលបានយុត្តិធម៌ដោយប្រសិទ្ធភាព មិនអាចកើតមានបានទេ ប្រសិនបើទីតាំងអាគាររបស់ទីភ្នាក់ងារប្រតិបត្តិច្បាប់ និងតុលាការ មិនបានបង្កលក្ខណៈងាយស្រួលជារូបវន្តទេ ឬប្រសិនបើសេវាកម្មព័ត៌មាននិងទំនាក់ទំនង ដែលផ្តល់ឲ្យនោះ មិនបង្កលក្ខណៈងាយស្រួលដល់ជនពិការ (មាត្រា១៣)។ លំនៅដ្ឋានសុវត្ថិភាព សេវាកម្ម និងនីតិវិធីគាំទ្រ ត្រូវតែបង្កលក្ខណៈងាយស្រួលដើម្បីផ្តល់ការការពារប្រកបដោយអត្ថន័យ និងមានប្រសិទ្ធភាពពីអំពើហិង្សា ការរំលោភបំពាន និងការកេងប្រវ័ញ្ចជនពិការ ជាពិសេសស្ត្រី និងកុមារ(មាត្រា១៦)។ បរិស្ថាន មធ្យោបាយដឹកជញ្ជូន ព័ត៌មាននិងទំនាក់ទំនង ព្រមទាំងសេវាកម្មដែលបង្កលក្ខណៈងាយស្រួល គឺជាបុរេលក្ខខណ្ឌមួយសម្រាប់ការដាក់បញ្ចូលជនពិការទៅក្នុងសហគមន៍មូលដ្ឋានរៀងៗខ្លួនរបស់ពួកគេ និងសម្រាប់ឲ្យពួកគេរស់នៅដោយឯករាជ្យ (មាត្រា១៩)។

៣៨. មាត្រា៩ និង២១ មានចំនុចប្រសព្វគ្នា ត្រង់បញ្ហាព័ត៌មាននិងទំនាក់ទំនង។ មាត្រា២១ ចែងថា រដ្ឋភាគី "ត្រូវចាត់វាល់វិធានការសមស្រប ដើម្បីធានាថា ជនពិការអាចអនុវត្តសិទ្ធិសេរីភាពរបស់ខ្លួនបានក្នុងការសម្តែងមតិយោបល់ រួមទាំងសេរីភាពក្នុងការស្វែងរកទទួល និងចែកចាយព័ត៌មាន និងទស្សនៈ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ និងតាមរយៈគ្រប់ទម្រង់នៃទំនាក់ទំនងតាមការជ្រើសរើសរបស់ខ្លួន"។ មាត្រានេះបានបន្ត

រៀបរាប់លម្អិតអំពីវិធី ដែលការបង្កលក្ខណៈងាយស្រួលនៃវិស័យព័ត៌មាននិងទំនាក់ទំនង ត្រូវបានធានា ក្នុងការអនុវត្តជាក់ស្តែង។ បញ្ញត្តិនេះ តម្រូវឲ្យរដ្ឋភាគី "ផ្តល់ព័ត៌មានដែលមានបំណងដល់សាធារណជន ឲ្យដល់ជនពិការតាមទម្រង់និងបច្ចេកវិទ្យាដែលមានការបង្កលក្ខណៈងាយស្រួល សមស្របទៅនឹងប្រភេទផ្សេងៗនៃពិការភាព(មាត្រា២១(ក))។ លើសពីនេះទៀត មាត្រានេះក៏ចែងអំពី "ការជួយសម្រួលដល់ការប្រើប្រាស់ភាសាសញ្ញា អក្សរស្ទាប និងទំនាក់ទំនងតាមបែបជំនួយ និងជំនួស ព្រមទាំងគ្រប់មធ្យោបាយដែលអាចប្រើប្រាស់បានផ្សេងៗទៀត របៀប និងទម្រង់នៃទំនាក់ទំនង តាមការជ្រើសរើសរបស់ជនពិការ ក្នុងអន្តរកម្មជាផ្លូវការ" (មាត្រា២១(ខ))។ អង្គភាពឯកជនដែលផ្តល់សេវាកម្មផ្សេងៗ ដល់សាធារណជនទូទៅ រួមទាំងតាមរយៈប្រព័ន្ធអ៊ីនធឺណែត ត្រូវបានជំរុញឲ្យផ្តល់ព័ត៌មាន និងសេវាកម្មផ្សេងៗ តាមទម្រង់ដែលជនពិការអាចទទួលបាន និងប្រើប្រាស់បាន(មាត្រា២១(គ)) ហើយមានការលើកទឹកចិត្តដល់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន រួមទាំងអ្នកផ្សព្វផ្សាយព័ត៌មានតាមអ៊ីនធឺណែត ដើម្បីធ្វើឲ្យជនពិការអាចប្រើប្រាស់សេវាកម្មរបស់ពួកគេបាន(មាត្រា២១(ឃ))។ មាត្រា២១នេះ ក៏តម្រូវឲ្យរដ្ឋភាគីទទួលស្គាល់ និងលើកស្ទួយការប្រើប្រាស់ភាសាសញ្ញាស្របតាមមាត្រា២៤ ២៧ ២៩ និង៣០ នៃអនុសញ្ញានេះ។

៣៩. បើគ្មានមធ្យោបាយដឹកជញ្ជូនដែលបង្កលក្ខណៈងាយស្រួលសម្រាប់ទៅសាលារៀន សំរាប់អាគារសាលារៀន ព្រមទាំងព័ត៌មាននិងទំនាក់ទំនងដល់ជនពិការទេ នោះជនពិការនឹងមិនអាចមានឱកាស ក្នុងការអនុវត្តសិទ្ធិទទួលបានការអប់រំរបស់ខ្លួនឡើយ (មាត្រា២៤ នៃអនុសញ្ញា)។ ដូច្នេះ សាលារៀនត្រូវតែបង្កលក្ខណៈងាយស្រួលដូចដែលមានចែងច្បាស់ក្នុងមាត្រា៩ កថាខណ្ឌ១(ក) នៃអនុសញ្ញា។ ទោះជាយ៉ាងណាក៏ដោយ វាគឺជាដំណើរការទាំង ស្រុងនៃការអប់រំដែលមានការដាក់បញ្ចូលដែលត្រូវតែបង្កលក្ខណៈងាយស្រួល មិនមែនបង្កលក្ខណៈងាយស្រួលត្រឹមតែអាគារប៉ុណ្ណោះទេ គឺត្រូវបង្កលក្ខណៈងាយស្រួលចំពោះព័ត៌មាននិងទំនាក់ទំនងរួមទាំងប្រព័ន្ធជំនួយជុំវិញ ឬFM សេវាគាំទ្រ និងដំណោះស្រាយសមហេតុផលតាមសាលារៀន។ ដើម្បីលើកកម្ពស់ការបង្កលក្ខណៈងាយស្រួល ការអប់រំគួរលើកស្ទួយ និងត្រូវធ្វើឡើងជាភាសាសញ្ញា អក្សរស្ទាប អក្សរជំនួស របៀបនៃការរៀនបែបជំនួយ និងជំនួស ព្រមទាំងមធ្យោបាយ និងទម្រង់ផ្សេងៗនៃទំនាក់ទំនង និងការតម្រង់ទិស ក៏ដូចជាខ្លឹមសារនៃកម្មវិធីសិក្សា (មាត្រា២៤ កថាខណ្ឌ៣(ក)) ដោយផ្តោតការយកចិត្តទុកដាក់ពិសេស ទៅលើភាសាសមរម្យព្រមទាំងរបៀប និងមធ្យោបាយនៃទំនាក់ទំនង ដែលប្រើប្រាស់ដោយសិស្សពិការភ្នែក ថ្លង់ និងពិការភ្នែក-ថ្លង់។ របៀប និងមធ្យោបាយនៃការបង្រៀន គួរតែមានការបង្កលក្ខណៈងាយស្រួល និង

គួរធ្វើឡើងក្នុងបរិស្ថានបង្កលក្ខណៈងាយស្រួល។ បរិស្ថានទាំងមូលសម្រាប់សិស្សពិការ ត្រូវតែរចនាឡើងតាមរបៀបដែលលើកកម្ពស់ការដាក់បញ្ចូល និងធានាពីគុណភាពក្នុងដំណើរការទាំងស្រុងនៃការអប់រំរបស់ពួកគេ។ ការអនុវត្តពេញលេញនៃមាត្រា២៤នៃអនុសញ្ញានេះ គួរត្រូវបានពិចារណារួមជាមួយនឹងលិខិតុបករណ៍សិទ្ធិមនុស្សសំខាន់ៗដទៃទៀត ព្រមទាំងបទប្បញ្ញត្តិនៃអនុសញ្ញាប្រឆាំងនឹងការរើសអើង ក្នុងវិស័យអប់រំរបស់អង្គការយូណេស្កូ។

៤០. ការថែទាំសុខភាព និងការការពារសង្គមនឹងនៅតែមិនអាចសម្រេចបានសម្រាប់ជនពិការទេ ប្រសិនបើពួកគេមិនអាចចេញ-ចូលក្នុងទីតាំងដែលត្រូវផ្តល់សេវាកម្មទាំងនេះបាននោះទេ។ ទោះបីជាអាគារដែលផ្តល់សេវាថែទាំសុខភាព និងសេវាកម្មការពារសង្គមទាំងនោះ បង្កលក្ខណៈងាយស្រួលក៏ដោយ បើគ្មានមធ្យោបាយដឹកជញ្ជូនដែលបង្កលក្ខណៈងាយស្រួលទេ ជនពិការក៏នៅតែមិនអាចធ្វើដំណើរទៅកន្លែងផ្តល់សេវាទាំងនោះបានដដែល។ គ្រប់ព័ត៌មាន និងទំនាក់ទំនង ដែលជាប់ពាក់ព័ន្ធនឹងបទប្បញ្ញត្តិអំពីការថែទាំសុខភាព គួរតែបង្កលក្ខណៈងាយស្រួលតាមរយៈភាសាសញ្ញា អក្សរស្ទាប ទម្រង់អេឡិចត្រូនិក ដែលបង្កលក្ខណៈងាយស្រួល អក្សរជំនួស របៀបនៃការរៀនបែបជំនួយ និងជំនួស ព្រមទាំងមធ្យោបាយ និងទម្រង់ផ្សេងៗនៃទំនាក់ទំនង។ វាជាប្រការ

សំខាន់យ៉ាងពិសេស ក្នុងការពិចារណាអំពីវិសាលភាពយេនឌ័រនៃការបង្កលក្ខណៈងាយស្រួល នៅពេលផ្តល់ការថែទាំសុខភាព ជាពិសេស ការថែទាំសុខភាពបន្តពូជសម្រាប់ស្ត្រី និងក្មេងស្រីពិការ រួមទាំងសេវារោគស្ត្រី និងសេវាសម្រាលកូនផង។

៤១. ជនពិការមិនអាចទទួលបានការងារ និងសិទ្ធិការងាររបស់ខ្លួនដោយប្រសិទ្ធភាពដូចមានចែងក្នុងមាត្រា២៧នៃអនុសញ្ញានេះបានទេ ប្រសិនបើទីកន្លែងធ្វើការនោះ មិនបង្កលក្ខណៈងាយស្រួល។ ដូច្នេះ កន្លែងធ្វើការត្រូវបង្កលក្ខណៈងាយស្រួល ដូចមានចែងយ៉ាងច្បាស់ក្នុងមាត្រា៩ កថាខណ្ឌ១(ក)។ ការបដិសេធមិនសម្របកន្លែងធ្វើការ គឺជាទង្វើនៃការរើសអើងដោយសារពិការភាពដែលត្រូវហាមឃាត់។ ក្រៅពីការបង្កលក្ខណៈងាយស្រួលជារូបវ័ន្តនៅកន្លែងធ្វើការ ជនពិការត្រូវការមធ្យោបាយធ្វើដំណើរ និងសេវាគាំទ្រដែលបង្កលក្ខណៈងាយស្រួល ដើម្បីជួយឲ្យពួកគេអាចធ្វើដំណើរដល់កន្លែងធ្វើការបាន។ រាល់ព័ត៌មានពាក់ព័ន្ធនឹងការងារ ការផ្សព្វផ្សាយអំពីការងារ ដំណើរការជ្រើសរើស និងទំនាក់ទំនងនៅកន្លែងធ្វើការ ដែលជាចំណែកមួយនៃដំណើរការការងារ ត្រូវតែបង្កលក្ខណៈងាយស្រួលតាមរយៈភាសាសញ្ញា អក្សរស្ទាប ទម្រង់អេឡិចត្រូនិកដែលបង្កលក្ខណៈងាយស្រួល អក្សរជំនួស របៀបនៃការរៀនបែបជំនួយ និងជំនួស ព្រមទាំងមធ្យោបាយ និងទម្រង់

ផ្សេងៗនៃទំនាក់ទំនង។ គ្រប់សហជីពនិងសិទ្ធិការងារ ក៏ត្រូវតែបង្កលក្ខណៈងាយស្រួលដែរ ដូចគ្នានឹងឱកាសនៃការបណ្តុះបណ្តាល និងគុណសម្បត្តិការងារដែរ។ ឧទាហរណ៍ វគ្គភាសាបរទេស ឬវគ្គកុំព្យូទ័រសម្រាប់បុគ្គលិក និងសិក្ខាកាមជន ត្រូវតែធ្វើឡើងនៅក្នុងបរិស្ថានមួយដែលបង្កលក្ខណៈងាយស្រួល តាមរូបមន្ត របៀបមធ្យោបាយ និងទម្រង់ដែលបង្កលក្ខណៈងាយស្រួល។

៤២. មាត្រា២៨ នៃអនុសញ្ញានេះ លើកឡើងអំពីជីវភាពរស់នៅសមរម្យ និងការការពារសង្គមកិច្ចដល់ជនពិការ។ រដ្ឋភាគីគួរចាត់វិធានការចាំបាច់ ដើម្បីធានាថា វិធានការ និងសេវាការពារផ្នែកសង្គមកិច្ចទាំងទូលាយ ទាំងជាក់លាក់ដល់ជនពិការ ត្រូវបានផ្តល់ឲ្យតាមវិធីបង្កលក្ខណៈងាយស្រួលក្នុងអាគារដែលបង្កលក្ខណៈងាយស្រួល និងគ្រប់ព័ត៌មាននិងទំនាក់ទំនងទាក់ទងនឹងបញ្ហាទាំងនេះ គួរបង្កលក្ខណៈងាយស្រួលតាមរយៈភាសាសញ្ញា អក្សរស្ទាបទម្រង់អេឡិចត្រូនិកដែលបង្កលក្ខណៈងាយស្រួល អក្សរជំនួសរបៀបនៃការរៀនបែបជំនួយ និងជំនួស ព្រមទាំងមធ្យោបាយ និងទម្រង់ផ្សេងៗនៃទំនាក់ទំនង។ កម្មវិធីលំនៅដ្ឋានសង្គមកិច្ចគួរផ្តល់លំនៅដ្ឋានដែលបង្កលក្ខណៈងាយស្រួលដល់ជនពិការ និងមនុស្សចាស់ផងដែរ ក្នុងចំណោមបញ្ហាផ្សេងៗទៀត។

៤៣. មាត្រា២៩ នៃអនុសញ្ញានេះ ធានាជនពិការនូវសិទ្ធិចូលរួមក្នុងជីវភាពនយោបាយនិងសាធារណៈ និងសិទ្ធិចូលរួមក្នុងការចាត់ចែងកិច្ចការសាធារណៈ។ ជនពិការនឹងមិនអាចប្រើប្រាស់សិទ្ធិទាំងនេះដោយស្មើភាពគ្នា និងដោយប្រសិទ្ធភាពទេ ប្រសិនបើរដ្ឋភាគីខកខានមិនបានធានាថា នីតិវិធី គ្រឿងសម្រួល និងសម្ភារៈបោះឆ្នោត មានលក្ខណៈសមរម្យ បង្កលក្ខណៈងាយស្រួល និងងាយស្រួលយល់ និងងាយស្រួលប្រើទេនោះ។ បញ្ហានេះមានសារសំខាន់ផងដែរថា ការប្រជុំ និងសម្ភារៈនយោបាយ ដែលប្រើប្រាស់និងផលិតដោយគណបក្សនយោបាយ ឬបេក្ខជនឯកត្តជនចូលរួមក្នុងការបោះឆ្នោតជាសាធារណៈនោះ ត្រូវតែមានការបង្កលក្ខណៈងាយស្រួល។ ប្រសិនបើមិនដូច្នោះទេ ជនពិការនឹងត្រូវបានគេដកហូតសិទ្ធិចូលរួមក្នុងដំណើរការនយោបាយដោយស្មើភាពគ្នាជាមួយអ្នកដទៃឡើយ។ ជនពិការ ដែលត្រូវបានបោះឆ្នោតឲ្យធ្វើការក្នុងការិយាល័យសាធារណៈ ត្រូវមានឱកាសស្មើភាពគ្នា ដើម្បីអនុវត្តអាណត្តិការងាររបស់ខ្លួន ក្នុងលក្ខណៈដែលមានការបង្កលក្ខណៈងាយស្រួលយ៉ាងពេញលេញ។

៤៤. បុគ្គលគ្រប់រូបមានសិទ្ធិចូលរួមក្នុងសិល្បៈ ចូលរួមក្នុងកីឡា និងទៅសណ្ឋាគារ ភោជនីយដ្ឋាន និងបារ។ ទោះជាយ៉ាងណាក៏ដោយ អ្នកជិះលើរទេះរុញ មិនអាចចូលរួមក្នុងការប្រគុំតន្ត្រី

បានទេ ប្រសិនបើសាលប្រគុំតន្ត្រីនោះមានតែជណ្តើរកាំ។ ជនពិការភ្នែកមិនអាចចូលរួមរីករាយនឹងផ្ទាំងគំនូរបានទេ ប្រសិនបើមិនមានការពណ៌នាជាសម្លេង ក្នុងវិចិត្រសាលនោះទេ។ ជនពិការពិបាកស្តាប់ មិនអាចរីករាយនឹងខ្សែភាពយន្តទេ ប្រសិនបើគ្មានអក្សររត់ខាងក្រោម។ ជនពិការថ្លង់ មិនអាចរីករាយនឹងការសម្តែងល្ខោនបានទេ ប្រសិនបើគ្មានការបកប្រែជាភាសាសញ្ញា។ ជនពិការបញ្ញាមិនអាចរីករាយនឹងសៀវភៅបានទេ ប្រសិនបើគ្មានសំណៅងាយស្រួលអាន ឬទម្រង់បែបជំនួស និងជំនួយណាមួយនោះទេ។ មាត្រា៣០ នៃអនុសញ្ញា តម្រូវឲ្យរដ្ឋភាគី ទទួលស្គាល់សិទ្ធិជនពិការចូលរួមក្នុងជីវភាពវប្បធម៌ ដោយឈរលើភាពស្មើគ្នាជាមួយអ្នកដទៃ។ ទាំងអស់នេះ តម្រូវឲ្យរដ្ឋភាគីចាត់វាល់វិធានការសមស្រប ដើម្បីធានាថា ជនពិការ៖

(ក) មានសិទ្ធិទទួលបានសម្ភារៈវប្បធម៌តាមទម្រង់ដែលគេអាចប្រើប្រាស់បាន។

(ខ) មានសិទ្ធិទទួលបានកម្មវិធីទូរទស្សន៍ ភាពយន្ត ល្ខោន និងសកម្មភាពវប្បធម៌ផ្សេងៗ ក្នុងទម្រង់ដែលគេអាចប្រើប្រាស់បាន។

(គ) មានសិទ្ធិចូលដល់ទីកន្លែងសម្រាប់ការសម្តែង ឬសេវាកម្មវប្បធម៌ ដូចជា រោងល្ខោន សារមន្ទីរ រោងភាពយន្ត បណ្ណាល័យ និងសេវាកម្មទេសចរណ៍ ព្រមទាំងតាមលទ្ធភាពដែលអាចធ្វើទៅបាន មានសិទ្ធិចូលដល់បូជនីយដ្ឋាន និងរមណីយដ្ឋានសំខាន់ៗរបស់វប្បធម៌ជាតិ។

ការផ្តល់នូវសិទ្ធិចូលទៅដល់បូជនីយដ្ឋានវប្បធម៌ និងប្រវត្តិសាស្ត្រ ដែលជាចំណែកនៃបេតិកភណ្ឌជាតិ តាមពិតទៅ អាចជាបញ្ហាប្រឈមមួយក្នុងកាលៈទេសៈខ្លះ។ ក៏ប៉ុន្តែ រដ្ឋភាគីមានកាតព្វកិច្ចប្រឹងប្រែងដើម្បីអាចឲ្យជនពិការចូលដល់ទីតាំងទាំងនោះបាន។ បូជនីយដ្ឋាន និងរមណីយដ្ឋានសំខាន់ៗរបស់វប្បធម៌ជាតិជាច្រើនត្រូវបានធ្វើឲ្យមានការបង្កលក្ខណៈងាយស្រួលតាមវិធីដែលអភិរក្សអត្តសញ្ញាណ និងលក្ខណៈពិសេសនៃវប្បធម៌ និងប្រវត្តិសាស្ត្របាន។

**៤៥.** "រដ្ឋភាគីត្រូវចាត់វិធានការសមស្របនានាដើម្បីឲ្យជនពិការអាចមានឱកាសបង្កើត និងប្រើប្រាស់សក្តានុពលខាងបញ្ញាសិល្បៈ និងគំនិតច្នៃប្រឌិតរបស់ខ្លួន" (មាត្រា៣០ កថាខណ្ឌ២)។ "រដ្ឋភាគីត្រូវចាត់រាល់វិធានការសមស្រប ស្របតាមច្បាប់អន្តរជាតិ ដើម្បីធានាថាច្បាប់ទាំងឡាយដែលការពារកម្មសិទ្ធិបញ្ញា នឹងមិន

បង្កើតជារបាំងមិនសមហេតុផល ឬរើសអើងដល់ការទទួលបានសម្ភារៈវប្បធម៌ដោយជនពិការឡើយ” (មាត្រា៣០ កថាខណ្ឌ៣)។ សន្ធិសញ្ញាម៉ារ៉ាកេស ដើម្បីជួយសម្រួលដល់សិទ្ធិទទួលបានស្នាដៃបោះពុម្ពផ្សាយសម្រាប់ជនពិការភ្នែក ជនដែលមានភាពអន់ខ្សោយក្នុងការមើល ឬជនមិនអាចមើលអក្សរបោះពុម្ពលើក្រដាសបានរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ដែលត្រូវបានអនុម័ត កាលពីខែមិថុនា ឆ្នាំ២០១៣ ត្រូវធានាឲ្យមានសិទ្ធិទទួលបានសម្ភារៈវប្បធម៌ ដោយគ្មានរបាំងមិនសមហេតុផល ឬរើសអើងសម្រាប់ជនពិការ រួមទាំងជនពិការរស់នៅបរទេស ឬជាសមាជិកនៃជនជាតិភាគតិចនៅប្រទេសដទៃ ដោយនិយាយ ឬប្រើប្រាស់ភាសា ឬមធ្យោបាយទំនាក់ទំនងដូចគ្នា ជាពិសេសសម្រាប់អ្នកដែលមានបញ្ហាប្រឈម ក្នុងការទទួលបានសម្ភារៈបោះពុម្ពជាលក្ខណៈប្រពៃណី។ អនុសញ្ញាស្ដីពីសិទ្ធិជនពិការចែងថា ដោយឈរលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ ជនពិការត្រូវមានសិទ្ធិបានការទទួលស្គាល់ និងការគាំទ្រនៃអត្តសញ្ញាណភាសា និងវប្បធម៌ជាក់លាក់របស់ខ្លួន។ មាត្រា៣០ កថាខណ្ឌ៤ សង្កត់ធ្ងន់អំពីការទទួលស្គាល់ និងការគាំទ្រភាសាសញ្ញា និងវប្បធម៌គ-ថ្លង់។

៤៦. មាត្រា៣០ កថាខណ្ឌ៥ នៃអនុសញ្ញា ចែងថា ដើម្បីជួយឲ្យជនពិការ អាចចូលរួមបានដោយស្មើភាពគ្នាជាមួយអ្នកដទៃក្នុងសកម្មភាពកីឡា ការលំហែ និងការកំសាន្តបាន រដ្ឋភាគីត្រូវចាត់វិធានការសមស្រប ដូចតទៅៈ

(ក) ជំរុញ និងលើកស្ទួយការចូលរួមរបស់ជនពិការក្នុងវិសាលភាពពេញលេញបំផុត ដែលអាចធ្វើទៅបានក្នុងការបញ្ជ្រៀបសកម្មភាពកីឡានៅគ្រប់កម្រិត។

(ខ) ធានាថា ជនពិការមានឱកាសរៀបចំ អភិវឌ្ឍ និងចូលរួមក្នុងសកម្មភាពកីឡា និងការកំសាន្តជាក់ស្តែងសម្រាប់ជនពិការ ហើយដើម្បីសម្រេចបានគោលដៅនេះ ត្រូវលើកទឹកចិត្តឲ្យមានការផ្តល់ការណែនាំ ការបណ្តុះបណ្តាល និងធនធានសមស្រប ដោយផ្អែកលើមូលដ្ឋានស្មើភាពគ្នាជាមួយអ្នកដទៃ។

(គ) ធានាថាជនពិការមានសិទ្ធិទទួលបានទីកន្លែងសម្រាប់លេងកីឡា ការកំសាន្ត និងទេសចរណ៍។

(ឃ) ធានាថា កុមារពិការមានសិទ្ធិទទួលបានការចូលរួមដោយស្មើភាពគ្នាជាមួយកុមារដទៃទៀត ក្នុងសកម្មភាពសម្តែង ការលំហែ ការកំសាន្ត និងកីឡារួមទាំងសកម្មភាពទាំងឡាយ នៅក្នុងប្រព័ន្ធសាលារៀនផង និង

(ង) ធានាថា ជនពិការមានសិទ្ធិទទួលបានសេវាកម្មពីអ្នកទាំងឡាយ ដែលពាក់ព័ន្ធនឹងការរៀបចំសកម្មភាពកីឡា ការលំហែ ទេសចរណ៍ និងការកំសាន្ត។

**៤៧.** កិច្ចសហប្រតិបត្តិការអន្តរជាតិដូចមានចែងក្នុងមាត្រា ៣២ នៃអនុសញ្ញា គួរតែជាឧបករណ៍ដ៏សំខាន់មួយ ក្នុងការលើកស្ទួយនូវការបង្កលក្ខណៈងាយស្រួល និងការរចនាប្លង់សកល។ គណៈកម្មាធិការ ផ្តល់អនុសាសន៍ដល់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិឲ្យទទួលស្គាល់ពីសារៈសំខាន់នៃការគាំទ្រគម្រោងទាំងឡាយដែលកែលម្អបច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនង ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធដែលបង្កលក្ខណៈងាយស្រួលដទៃទៀត។ ការវិនិយោគថ្មីៗទាំងអស់ ដែលធ្វើឡើងក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការអន្តរជាតិ គួរត្រូវបានប្រើ ដើម្បីលើកទឹកចិត្តឲ្យមានការលុបបំបាត់របាំងដែលមានក្នុងពេលបច្ចុប្បន្ននិងបង្ការកុំឲ្យមានការបង្កើតរបាំងថ្មីៗទៀត។ នេះជាការមិនអាចទទួលយកបានទេ ក្នុងការប្រើប្រាស់មូលនិធិសាធារណៈ ដើម្បីបង្កើតឲ្យមានវិសមភាពថ្មីទៀតនោះ។ រាល់វត្ថុហេដ្ឋារចនាសម្ព័ន្ធ គ្រឿងសម្រួល ទំនិញ ផលិតផល និងសេវាកម្មថ្មីៗ ត្រូវតែបង្កលក្ខណៈងាយស្រួលពេញលេញដល់ជនពិការ។ កិច្ចសហប្រតិបត្តិការអន្តរជាតិ គួរត្រូវបានប្រើ មិនមែនសម្រាប់តែវិនិយោគទៅលើទំនិញ ផលិតផល និងសេវាកម្មដែលបង្កលក្ខណៈ

ងាយស្រួលមួយមុខនោះទេ តែក៏គួរប្រើប្រាស់ដើម្បីលើកកម្ពស់ការផ្លាស់ប្តូរជំនាញ និងព័ត៌មានអំពីការអនុវត្តល្អៗ ក្នុងការសម្រេចឲ្យបាននូវការបង្កលក្ខណៈងាយស្រួល តាមរបៀបដែលនឹងធ្វើឲ្យមានការផ្លាស់ប្តូរជាក់ស្តែង ដែលអាចកែលម្អជីវភាពរបស់ជនពិការរាប់លាននាក់ពាសពេញពិភពលោក។ កិច្ចសហប្រតិបត្តិការអន្តរជាតិអំពីបទដ្ឋានីយកម្ម ក៏មានសារៈសំខាន់ផងដែរ ដោយសារថាអង្គការជនពិការត្រូវតែទទួលបានការគាំទ្រ ឲ្យពួកគេអាចចូលរួមក្នុងដំណើរការថ្នាក់ជាតិ និងអន្តរជាតិ ដើម្បីបង្កើត អនុវត្ត និងតាមឃ្លាំមើលបទដ្ឋាននៃការបង្កលក្ខណៈងាយស្រួល។ ការបង្កលក្ខណៈងាយស្រួល ត្រូវតែជាចំណែកដ៏មានសារសំខាន់បំផុតនៃកិច្ចខំប្រឹងប្រែងអភិវឌ្ឍន៍ប្រកបដោយចីរភាពណាមួយ ជាពិសេស ក្នុងបរិបទនៃរបៀបវារៈក្រោយឆ្នាំ២០១៥។

៤៨. ការតាមឃ្លាំមើលពីការបង្កលក្ខណៈងាយស្រួល គឺជាទិដ្ឋភាពដ៏សំខាន់មួយនៃការតាមឃ្លាំមើលថ្នាក់ជាតិ និងអន្តរជាតិទៅលើអនុសញ្ញានេះ។ មាត្រា៣៣ តម្រូវឲ្យរដ្ឋភាគី បង្កើតមន្ត្រីបង្គោលក្នុងរដ្ឋាភិបាល សំរាប់បញ្ហានានាដែលពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញានេះ ក៏ដូចជា ក្របខណ្ឌថ្នាក់ជាតិដែលរួមមានយន្តការឯករាជ្យមួយ ឬច្រើន។ សង្គមស៊ីវិលគួរតែមានការពាក់ព័ន្ធ និងចូលរួមពេញលេញក្នុងដំណើរការតាមឃ្លាំមើលនេះ។ វាជាការ

សំខាន់ដែលស្ថាប័ននានាចែងក្នុងមាត្រា៣៣នេះ ត្រូវបានពិគ្រោះយោបល់ត្រឹមត្រូវនៅពេលពិចារណាអំពីវិធានការសម្រាប់អនុវត្តឲ្យបានត្រឹមត្រូវនៃមាត្រា៩។ ស្ថាប័នទាំងនេះគួរមានឱកាសគ្រប់គ្រាន់ចូលរួម ក្នុងការរៀបចំសេចក្តីព្រាងបទដ្ឋានស្តីពីការបង្កលក្ខណៈងាយស្រួលនៅថ្នាក់ជាតិ ការផ្តល់មតិយោបល់ទៅលើសេចក្តីព្រាងច្បាប់ និងច្បាប់ដែលមានស្រាប់ ការដាក់សំណើចំពោះសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិគោលនយោបាយ ព្រមទាំងចូលរួមពេញលេញក្នុងការលើកកម្ពស់ការយល់ដឹង និងយុទ្ធនាការអប់រំនានា។ ដំណើរការនៃការតាមឃ្លាំមើលថ្នាក់ជាតិ និងអន្តរជាតិ ពីការអនុវត្តអនុសញ្ញានេះ គួរធ្វើឡើងតាមបែបបទ ដែលបង្កលក្ខណៈងាយស្រួល ដែលលើកស្ទួយ និងធានាឲ្យមានការចូលរួមដោយប្រសិទ្ធភាពរបស់ជនពិការ និងអង្គការតំណាងជនពិការនានា។ មាត្រា៤៩ នៃអនុសញ្ញានេះ តម្រូវថា អត្ថបទនៃអនុសញ្ញានេះ ត្រូវធ្វើឲ្យមានជាទម្រង់មួយដែលជនពិការអាចប្រើប្រាស់បាន។ នេះគឺជាគំនិតច្នៃប្រឌិតមួយក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ហើយអនុសញ្ញាសិទ្ធិជនពិការ គួរត្រូវបានមើលឃើញថា ជាការបង្កើតករណីយុត្តិសាស្ត្រមួយចំពោះការងារនេះ សម្រាប់សន្ធិសញ្ញាទាំងអស់នាពេលអនាគត។